ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY


## សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ដំណើរការជួញដូរមូលបត្រជាសាធារណៈ នៅកម្ពុជា

# PUBLIC SECURITIES TRADING PROCESS IN CAMBODIA

### ជំនាញ គណនេយ្យ


រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

ក្រសួងអប់រំ យុវជន និងកីឡា
MINISTRY OF EDUCATION YOUTH AND SPORTS
សាកលវិទ្យាល័យវ៉ាន់ដា
VANDA UNIVERSITY

សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ដំណើរការជួញដូរមូលបត្រជាសាធារណៈនៅកម្ពុជា

# PUBLIC SECURITIES TRADING PROCESS IN CAMBODIA

គ្រូណែនាំ៖ ហឿង ម៉ុក

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥
PHNOM PENH-2025

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២២**

**ប្រធានបទ៖ ដំណើរការជួញដូរមូលបត្រជាសាធារណៈនៅកម្ពុជា**

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត មាស សំណាង

គ្រូណែនាំ

ហឿង ម៉ុក

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉ែម សុខហៀក

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

ប្រធានគណៈកម្មការវាយតម្លៃ និងជានាយក
មជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

អនុប្រធានគណៈកម្មការវាយតម្លៃ និងជានាយករង
មជ្ឈមណ្ឌលស្រាវជ្រាវ

បេក្ខបណ្ឌិត ស្រេង ផល្លា

**សាកលវិទ្យាធិការ**

**បណ្ឌិត ហេង វ៉ាន់ដា**

សាកលវិទ្យាធិការរងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

# អារម្ភកថា

ក្រុមយើងខ្ញុំបានរៀបចំចងក្រង និងសិក្សាស្រាវជ្រាវ សៀវភៅនេះឡើងក្រោយពីការសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ នៃសាកលវិទ្យាល័យវ៉ាន់ដា អស់រយៈពេល៣ឆ្នាំ ២ខែរួចមកក្នុងគោលបំណងបង្កើនចំណេះដឹង និង ដើម្បីអភិវឌ្ឍន៍ខ្លួន និងពង្រីកការយល់ដឹងបន្ថែមលើការសិក្សាកន្លងមក។

ផ្សារមូលបត្រកម្ពុជា (Cambodia Securities Exchange ) គឺជាផ្សារមូលបត្រទី១ ដំបូងគេបង្កស់ជាប្រវត្តិសាស្ត្រ របស់កម្ពុជាដែលមានតួនាទីចម្បងក្នុងការធានាតម្លាភាព និងបង្កើតបរិយាកាសការងារដែលមានភាពល្អប្រសើរដល់អ្នកចូលរួមក្នុងទីផ្សារ ជាពិសេសនៅក្នុង ក្រុមហ៊ុនក្នុងស្រុកដែលត្រូវការមូលធនដើម្បីពង្រីកអាជីវកម្ម ព្រមជាមួយនឹងការ ការពារផលប្រយោជន៍របស់វិនិយោគិនជាតិ និងអន្តរជាតិផងដែរ។ ផ្សារមូលបត្រកម្ពុជា ក៏បានដាក់ឱ្យ ដំណើការសម្រាប់ការចុះបញ្ជី របស់ក្រុមហ៊ុនចុះបញ្ជី សក្តានុពលដែល មានស្តង់ដារ និង ទំហំធំ។

ឯកសារនេះទុកជំនួយស្មារតី និងយល់ដឹងពីការជួញដូរមូលបត្រនៅកម្ពុជា ដើម្បីជាឯកសារដល់អ្នកសិក្សាជំនាន់ក្រោយ ដើម្បីសិក្សាស្រាវជ្រាវនិងយល់ដឹងបន្ថែមទៀត។ ទោះជាយ៉ាងណាក៏ដោយចំណេះដឹងនិងបទពិសោធន៍របស់យើងខ្ញុំនៅមានកម្រិតនៅឡើយ។ ដូច្នេះហើយការរៀបចំសៀវភៅសារណាមួយនេះនៅមានចន្លោះខ្វះខាតនៅឡើយ។

យ៉ាងដូច្នេះហើយយើងខ្ញុំនឹងរង់ចាំទទួលការរិះគន់ និងផ្តល់មតិយោបល់នៅក្នុងន័យស្ថាបនា និងកែលម្អបន្ថែមទៀតពីសំណាក់លោកគ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យគ្រប់រូបដោយក្តីរីករាយ។

ជាចុងក្រោយយើងខ្ញុំ សូមជូនពរដល់សិស្សប្អូនដែលជានិស្សិតកំពុងសិក្សានៅសាកលវិទ្យាល័យវ៉ាន់ដាជំនាន់ក្រោយទាំងអស់ខិតខំសិក្សារៀនសូត្រដើម្បី ទទួលបានជោគជ័យទាំងការសិក្សា និងគ្រប់ភារកិច្ចទាំងឡាយ។

# រចនាសម្ព័ន្ធ



**មូរ៉ា ស៊ីណាន**
ID：Sp22/028



**ប៊ិ សៀវយី**
ID :B22/004



**លីម ស្រីអូន**
ID:B22/009



**អូន មុន្នី**
ID: B22/061



**ទ៉េង លីហ៊ុយ**
ID:B22/018

# សេចក្តីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំ ជានិស្សិតនៃ សាកលវិទ្យាល័យវ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ ទី២២ ជំនាញ គណនេយ្យ

**សូមសំដែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំ ក្នុងការសិក្សារៀនសូត្រដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមយើងខ្ញុំសូមសំដែងនូវការគោរព និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណ ដែលបានផ្តល់កំណើតដល់យើងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្តាសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូទាំងអស់ ដែលបានបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសំដែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** នាយកនៃ សាកលវិទ្យាល័យវ៉ាន់ដាដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះលោកគ្រូ **ហឿង ម៉ុក** ជាសាស្ត្រាចារ្យណែនាំ ដោយបានជួយជ្រោមជ្រែង បង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណា នេះជាស្ថាពរ។
សូមគោរពថ្លែងអំណរគុណដល់សាស្ត្រាចារ្យ និងបុគ្គលិកនៃសាកលវិទ្យាល័យវ៉ាន់ដាទាំងអស់ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំ រហូតធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

## អំណះអំណាង

ក្រុមយើងខ្ញុំ ជានិស្សិតបរិញ្ញាបត្រ ជំនាញគណនេយ្យនៃសាកលវិទ្យាល័យវ៉ាន់ដា ជំនាន់ទី២២៖

សូមធានាអះអាងថា ខ្លឹមសារសារណាក្រោមប្រធានបទ “**ដំណើរការជួញដូរមូលបត្រជាសាធារណៈនៅកម្ពុជា**” នេះគឺជាស្នាដៃរបស់ក្រុមយើងខ្ញុំ ដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលនៃការស្រាវជ្រាវ ដែលលើកឡើងនេះ ជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃ ពុធ..៨កើត ខែ..កត្តិក... ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ថ្ងៃទី..២៩.... ខែ..តុលា.. ឆ្នាំ២០២៥

**ហត្ថលេខាតំណាងក្រុម**



បូរ៉ា ស៊ីណាន

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

ផ្សារមូលបត្រ គឺជាកន្លែងទិញលក់មូលបត្រ ដូចជាបណ្ណភាគហ៊ុន(Stock) បណ្ណបំណុល(Bond)និងឧបករណ៍ហិរញ្ញវត្ថុ(Other Securities) ផ្សេងៗទៀត។ មូលបត្រ(Security) ចែកចេញជាពីរគឺ មូលបត្រកម្មសិទ្ធិ(Equity Security) និងមូលបត្របំណុល (Debt Security)។

ផ្សារមូលបត្រដើរតួរយ៉ាងសំខាន់ក្នុងវិស័យសេដ្ឋកិច្ចរបស់ប្រទេសនីមួយៗ ដោយអនុញ្ញាតឱ្យក្រុមហ៊ុនសាជីវកម្មសហគ្រាសសាធារណៈនិងរដ្ឋាភិបាលប្រមូលទុនដោយផ្ទាល់ពីសាធារណៈជន មកប្រើប្រាស់ដើម្បីពង្រីកអាជីវកម្មឬអភិវឌ្ឍហេដ្ឋារចនាសម្ពន្ធជាដើម។

អ្នកដែលមានប្រាក់សល់ពីការចំណាយមានជម្រើសក្នុងការវិនិយោគរបស់ខ្លួន ឬធ្វើការសន្សំនៅក្នុងទីផ្សារមូលមត្របន្ថែមទៀត។ នៅប្រទេសកម្ពុជា ក៏ទើបតែបានដាក់ឱ្យដំណើរការផ្សារមូលបត្ររបស់ខ្លួនជាលើកដំបូងដែលមានឈ្មោះថា "ផ្សារមូលបត្រកម្ពុជា"ដោយមានការចូលរួមគ្នារវាងរដ្ឋាភិបាលកម្ពុជា(៥៥%) និងផ្សារមូលបត្រកូរ៉េ(៤៥%)។

ផ្សារមូលបត្រ គឺជាផ្នែកមួយសំខាន់មួយក្នុងប្រពន្ធ័ហិរញ្ញវត្ថុជាតិដើម្បីគៀងគរប្រភពហិរញ្ញវត្ថុផ្សេងៗមកអភិវឌ្ឍន៍សេដ្ឋកិច្ចឱ្យមានល្បឿនកាន់តែខ្ពស់។ ដើម្បីសម្រេចឱ្យបាននូវការអភិវឌ្ឍប្រទេសកម្ពុជា ដោយឈរលើគោលដៅ ក្នុងការជម្រុញកំណើនសេដ្ឋកិច្ចតាមរយៈលំហូរមូលធន ការវិយោគនិងការវិភាជន៍ជាថ្មីនូវមូលធនតាមរយៈយន្តការទីផ្សារមូលបត្រ នៅខែវិច្ឆិកា ឆ្នាំ២០០៦ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជានិងក្រុបហ៊ុនផ្សារមូលបត្រកូរ៉េបានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ស្តីពី"ការអភិវឌ្ឍផ្សារបត្រនៅព្រះរាជាណាចក្រកម្ពុជា"។ ដោយផ្អែកលើអនុស្សារណៈយោគយល់គ្នានេះ សម្តេចអគ្គសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ បានបង្កើតផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា" ត្រូវបានចុះហត្ថលេខាដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រនៅកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។

# មាតិកា

ទំព័រ


អារម្ភកថា ........ i
រចនាសម្ព័ន្ធក្រុម ........ ii
សេចក្តីថ្លែងអំណរគុណ ........ iii
អំណះអំណាង ........ iv
សេចក្តីសង្ខេបនៃការស្រាវជ្រាវ ........ v
មាតិកា ........ vi


## ជំពូកទី១
## សេចក្តីផ្តើម


១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២
១.៣ គោលបំណងនៃការស្រាវជ្រាវ ........ ២
១.៤ ទំហំ ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ ........ ២
១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ២
១.៦ សារៈសំខាន់នៃកាស្រាវជ្រាវ ........ ៣
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣


## ជំពូកទី២
## ដំណើរការជួញដូរមូលបត្រជាសារធារណៈ


២.១ លក្ខណៈទូទៅនៃការជួញដូរមូលបត្រ ........ ៥
២.១.១និយមន័យមូលបត្រ ........ ៥
២.១.២ ប្រវត្តិនៃមូលបត្រ ........ ៥
២.១.៣ លក្ខណៈនៃមូលបត្រ ........ ៥
២.១.៤ទ្រឹស្តីពាក់ព័ន្ធ ........ ៧
២.២ ដំណើរការជួញដូរមូលបត្រជាសារធារណៈនៅកម្ពុជា ........ ៨
២.២.១ និយមន័យការជួញដូរ ........ ៨
២.២.២ ប្រវត្តិនៃកាតព្វកិច្ច ........ ៨
២.២.៣ អត្ថប្រយោជន៍វិស័យមូលបត្រ ........ ៩
២.៣ ការជួញដូរមូលបត្រជាសារធារណៈនៅកម្ពុជាមានអត្ថប្រយោជន៍ទបែបណាខ្លះសម្រាប់សេដ្ឋកិច្ច?៩
២.៣.១ និយមន័យសេដ្ឋកិច្ច ........ ៩
២.៣.២ប្រវត្តិសេដ្ឋកិច្ច ........ ១០
២.៣.៣ ប្រព័ន្ធនៃសេដ្ឋកិច្ចសំខាន់ៗ ........ ១០

## ជំពូកទី៣
## ដំណើរការជួញដូរមូលបត្រជាសាធារណៈនៅកម្ពុជា


៣.១ ស្ថានភាពទូទៅរបស់ទីផ្សារមូលបត្រ ........ ១២
៣.១.១ ប្រវត្តិរបស់ទីផ្សារមូលបត្រ ........ ១៣
៣.១.២ បេសកកម្មនិងទស្សនវិស័យ ........ ១៣
៣.១.៣ រចនាសម្ព័ន្ធរបស់ក្រុមហ៊ុន ........ ១៣
៣.២ ដំណើរការនៃការជួញដូរមូលបត្រនៅកម្ពុជា ........ ១៤
៣.២.១គណៈកម្មការមូលបត្រកម្ពុជា ........ ១៤
៣.២.២ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតចុះបញ្ជី ........ ១៦
៣.២.៣ ផ្សារមូលបត្រកម្ពុជា ........ ១៩
៣.២.៤ ក្រុមហ៊ុនមូលបត្រ ........ ២០
៣.២.៥ ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ........ ២៣
៣.២.៦ អ្នកចូលរួមផ្សេងៗទៀត ក្នុងទីផ្សារមូលបត្រ ........ ២៦
៣.២.៧ វិនិយោគិន ........ ៣១
៣.៣ ផលប្រយោជន៍នៃការជួញដូរមូលបត្រចំពោះសេដ្ឋកិច្ច ........ ៣៤
៣.៣.១ផលប្រយោជន៍របស់ទីផ្សារមូលបត្រ ........ ៣៤
៣.៣.២ផលប្រយោជន៍ប្រព័ន្ធទីផ្សារមូលបត្រ ........ ៣៥
៣.៣.៣អត្ថប្រយោជន៍ទីផ្សាភាគហ៊ុនចំពោះវិនិយោគគិន ........ ៣៥


## ជំពូកទី៤
## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ


៤.១ ការវិភាគលើចំណុចខ្លាំង ........ ៣៩
៤.២ ការវិភាគលើចំណុចខ្សោយ ........ ៤០


## ជំពូកទី៥
## សេចក្ដីសន្និដ្ឋាន និងការផ្ដល់អនុសាសន៍


៥.១ សេចក្ដីសន្និដ្ឋាន ........ ៤១
៥.២ ការផ្ដល់អនុសាសន៍ ........ ៤១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

នៅពេលបច្ចុប្បន្នប្រទេសកម្ពុជា ជាប្រទេសមួយដែលកំពុងអភិវឌ្ឍន៍គ្រប់វិស័យ។ ជាមួយគ្នានេះដែលក្នុងការអភិវឌ្ឍន៍ប្រទេសឱ្យមានការរីកចម្រើនរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ និងអំពាវនាវដល់សហគមន៍និងដៃគូរសហការទាំងក្នុង និងក្រៅប្រទេសដើម្បីធ្វើឱ្យសេដ្ឋកិច្ចជឿនលឿន និងមាននិន្នាការឆ្ពោះទៅរកភាពជោគជ័យ។ ទន្ទឹមនិងនេះ វិស័យមូលបត្រក៏ជាសសៃរឈាមយ៉ាងសំខាន់ សម្រាប់សេដ្ឋកិច្ចជាតិទាំងមូលដែលក្រុមហ៊ុនបោះផ្សាយមូលបត្រ និងវិនិយោគិនជាអ្នកដើរតួនាទីស្នូល។ គ្រប់ប្រទេសទាំងអស់ នៅលើសកលលោក តែងតែផ្តោតទៅលើការយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការបង្កើត និងអភិវឌ្ឍន៍ទីផ្សារនេះដើម្បីធានា បាននូវប្រព័ន្ធហិរញ្ញវត្ថុប្រកបដោយភាពរឹងមាំ និងចីរភាពក្នុងទិសដៅរក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។ ផ្សារមូលបត្រគឺជាកន្លែងទិញលក់មូលបត្រ ដូចជាបណ្ណ័ភាគហ៊ុន (Stock) បណ្ណ័បំណុល( Bond) និងឧបករណ៍ហិរញ្ញវត្ថុ( Other Securities )ផ្សេងៗទៀត។ ផ្សារមូលបត្រដើរតួរយ៉ាងសំខាន់ក្នុងវិស័យសេដ្ឋកិច្ចសម្រាប់ប្រទេសនីមួយៗ ដោយអនុញ្ញាតឱ្យក្រុមហ៊ុនសាជីវកម្ម សហគ្រាសសាធារណៈ និងរាជរដ្ឋាភិបាលអាចប្រមូលទុនដោយផ្ទាល់ពីសាធារណៈជនមកប្រើប្រាស់ដើម្បីពង្រីកអាជីវកម្ម ឬអភិវឌ្ឍន៍ហេដ្ឋារចនាសម្ពន្ធ័ជាដើម។ ម្យ៉ាងវិញទៀតអ្នកដែលមានប្រាក់សល់ពីការចំណាយមានជម្រើសក្នុងការវិនិយោគរបស់ខ្លួន ឬធ្វើការសន្សំនៅក្នុងទីផ្សារមូលបត្របន្ថែមទៀត។ នៅប្រទេសកម្ពុជា ក៏ទើបតែបានដាក់ឱ្យដំណើរការផ្សារមូលបត្ររបស់ខ្លួន ជាលើកដំបូងដែលមានឈ្មោះថា **"ផ្សារមូលបត្រកម្ពុជា"** ដោយមានការចូលរួមរវាងរដ្ឋាភិបាលកម្ពុជា (៥៥%) និងផ្សារមូលបត្រកូរ៉េ (៤៥%)។

ផ្សារមូលបត្រ ជាផ្នែកមួយយ៉ាងសំខាន់ណាស់នៅក្នុងប្រព័ន្ធហិរញ្ញវត្ថុជាតិ ដើម្បីគៀងគរផ្សេងៗមកធ្វើការអភិវឌ្ឍសេដ្ឋកិច្ចឱ្យមានល្បឿនកាន់តែខ្ពស់។ វត្តមាននៃទីផ្សារមូលបត្រនឹងផ្តល់ជម្រើសដល់ការវិនិយោគថ្មីៗបន្ថែមទៀតក្រៅពីការកម្ចីពីការធនាគារ។ ទីផ្សារមូលបត្រទាំងមូលដែលអាចដំណើរការទៅបាននេះ គឺស្ថិតក្រោមច្បាប់ និងបទបញ្ញាត្តិនានានៃទីផ្សារមូលបត្រ គឺមានគោលបំណងជួយពង្រឹងនិងធានាថាប្រព័ន្ធទីផ្សារមូលបត្រមានភាពត្រឹមត្រូវនិងមានប្រសិទ្ធិភាព។ រាល់ប្រតិបត្តិការទាំងអស់ដែលពាក់ព័ន្ធក្នុងវិស័យមូលបត្រទាំងមូល គឺស្ថិតក្រោមបទបញ្ញាត្តិយ៉ាងពិសេសដោយតម្រូវឱ្យមានការដាក់បង្ហាញព័ត៌មាននានាជាសាធារណៈ និងកាត់បន្ថយការក្លែងបន្លំដែលផ្ទុយពីច្បាប់ និងបទបញ្ញាត្តិនានានៃទីផ្សារមូលបត្រឱ្យមតូចក្នុងកម្រិតអវសាន្ត។ ច្បាប់ និងបទបញ្ញាត្តិត្រូវបានគេអនុវត្តដើម្បីគ្រប់គ្រងរាល់ព័ត៌មានទាំងនៅលើទីផ្សារព្រមទាំងដំណើរការជួញដូរមូលបត្រផងដែរ។ ការធ្វើដូចនេះ គឺធ្វើឱ្យវិនិយោគិនម្នាក់ៗអាចទទួលបានព័ត៌មានដូចគ្នានៅក្នុងពេលតែមួយហើយមានឱកាសដូចគ្នាក្នុងការជួញដូរមូលបត្រ។

ដើម្បីសម្រេចបានការអភិវឌ្ឍន៍ប្រទេសកម្ពុជា ដោយឈរលើគោលដៅក្នុងការជម្រុញកំណើនសេដ្ឋកិច្ចតាមរយៈលំហូរមូលធន ការវិនិយោគ និងការវិភាជន៍ជាថ្មីនូវមូលធនតាមរយៈយន្តការទេតិផ្សារមូលបត្រនៅខែ វិច្ឆិកា ឆ្នាំ២០០៦ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េបានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ស្តីអំពី **"ការអភិវឌ្ឍន៍ផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា"**

។ ដោយមើលឃើញពីចំណុចសំខាន់ៗដែលបានរៀបរាប់ខាងលើ ទើបក្រុមយើងខ្ញុំសម្រេចជ្រើសរើសប្រធានបទមួយស្តីអំពី **"ដំណើរការជួញដូរមូលបត្រជាសាធារណៈនៅកម្ពុជា"** និងរៀបចំជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ការជួញដូរមូលបត្រ គឺមានសារៈសំខាន់ណាស់សម្រាប់សេដ្ឋកិច្ចជាតិ ព្រោះវាបានចូលរួមចំណែកក្នុងថវិកាជាតិ ដោយបានប្រមូលពន្ធពីក្រុមហ៊ុនចុះបញ្ជី និងជម្រុញឱ្យមានវិនិយោគគិន និងជាផ្នែកមួយនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិឱ្យមានការរីកចម្រើនផងដែរ។

ហេតុដូចនេះទើបក្រុមយើងខ្ញុំមានសំណួរមួយចំនួនមកចោទសួរដូចខាងក្រោម៖

១.តើការជួញដូរមូលបត្រជាសារធារណៈនៅកម្ពុជាមានដំណើរការយ៉ាងដូចម្តេច?

២.តើវិស័យមូលបត្រនៅកម្ពុជាមានអត្ថប្រយោជន៍ដល់សេដ្ឋកិច្ចបែបណាខ្លះ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវគឺបង្ហាញពីយន្តាការនៃការជួញដូរមូលបត្រនៅកម្ពុជាដោយផ្តោតលើ៖

- យល់ដឹងពីប្រវត្តនៃទីផ្សារមូលបត្រនៅកម្ពុជា
- យល់ដឹងពីគោលនយោបាយ បេសកកម្ម និង ទស្សនវិស័យរបស់ផ្សារមូលបត្រ
- យល់ដឹងពីតួនាទីនិង ភារៈកិច្ចរបស់ផ្សារមូលបត្រនៅកម្ពុជា
- យល់ដឹងពីអ្នកចូលរួមជួញដូរមូលបត្រនៅកម្ពុជា។

## ១.៤ ទំហំ ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំ និងដែនកំណត់

ការសិក្សាស្រាវជ្រាវនេះ គឺសិក្សាទៅលើ "**ការជួញដូរមូលបត្រជាសារធារណៈនៅកម្ពុជា**"។

### ១.៤.២ វិសាលភាព

តាមច្បាប់ស្តីពីការជួញដូរមូលបត្រនៅកម្ពុជា ត្រូវបានបង្កើតឡើងជាយូរណាស់មកហើយដោយមានពេលវេលាកំណត់ការសិក្សាស្រាវជ្រាវ និងស្វែងយល់អំពីដំណើរការនៃការជួញដូរមូលបត្រនៅកម្ពុជារបស់ផ្សារមូលបត្រកម្ពុជា (ផ.ម.ក) ទើបក្រុមយើងខ្ញុំសម្រេចធ្វើការស្រាវជ្រាវតែក្នុងអំឡុងឆ្នាំ២០២៣ តែប៉ុណ្ណោះ។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

### ១.៥.១ វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ បានប្រើប្រាស់វិធីសាស្រ្តតាមបែបគុណវិស័យសម្រាប់រៀបរាប់ និងការប្រមូលទិន្នន័យតាមរយៈប្រព័ន្ធអិនធឺណេត លើគេហទំព័ររបស់ផ្សារមូលបត្រនៅកម្ពុជា និងតាមរយៈការពិភាក្សាជាមួយគ្រូដឹកនាំ។ ដោយឯកសារដែលក្រុមយើងខ្ញុំប្រមូលត្រូវបានរៀបចំតាមលំដាប់លំដោយជាផ្នែកៗ ទៅតាមខ្លឹមសារអត្ថន័យនៃឯកសារនីមួយៗ ដោយឡែកៗពីគ្នាដើម្បី ងាយស្រួលក្នុងការសរសេរកិច្ចការស្រាវជ្រាវឱ្យកាន់តែល្អប្រសើរ។

**សម្រាប់សំណួរស្រាវជ្រាវទី១៖** ពាក់ពន្ធ័ទៅនឹងការសិក្សាស្រាវជ្រាវនេះ គឺប្រមូលទិន្នន័យតាមបែបគុណវិស័យដោយធ្វើឡើងតាមរយៈការដកស្រង់ទិន្នន័យដែលមានស្រាប់តាមរយៈគេហទំព័រផ្លូវការ របស់ផ្សារមូលបត្រនៅកម្ពុជា ដែលមានទីតាំង នៅអាគារ ផមក វិថីព្រះមហាក្សត្រីយានី កុសុមៈ(ផ្លូវ១០៦)សង្កាត់ វត្តភ្នំ

ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។ ដើម្បីផ្តល់ព័ត៌មានសម្រាប់អ្នកវិនិយោគយកទៅធ្វើការវិភាគ វាយតម្លៃ និង ធ្វើការសម្រេចចិត្តក្នុងការធ្វើ ការវិនិយោគទទួលបានលទ្ធផល ហើយមានប្រសិទ្ធភាព។

**សម្រាប់សំណួរស្រាវជ្រាវទី២៖** ពាក់ពន្ធ័ទៅនឹងការសិក្សាស្រាវជ្រាវនេះ គឺប្រមូលទិន្នន័យតាមបែបគុណវិស័យ ដូចសំណួរខាងលើដែរ (ផ្តោតទៅលើដំណើរការជួញដូរមូលបត្រជាសាធារណៈនៅកម្ពុជា) ដែលមានសារសំខាន់ដល់អ្នកដែលមានបំណងចង់ធ្វើការវិនិយោគនានាដូចជា៖ អ្នកធ្វើអាជីវកម្ម អ្នកវិនិយោគ អ្នកសិក្សាលើទីផ្សារ អ្នកវាយតម្លៃទីផ្សារ អ្នកសេដ្ឋកិច្ចទូទៅ ដើម្បីរៀបចំគោលនយោបាយ ដើម្បីទប់ស្កាត់ហានិភ័យលើសកម្មភាពទីផ្សារមូលបត្រ ក្នុងការគ្រប់គ្រងការវិនិយោគទុនឱ្យមានប្រសិទ្ធភាព និងមានប្រសិទ្ធផល។

**១.៥.២ ការប្រមូលទិន្នន័យបន្ទាប់**

ការប្រមូលទិន្នន័យបន្ទាប់គឺប្រមូលតាមរយៈនិក្ខេបបទរៀមច្បង តាមរយៈរៀមច្បង តាមរយៈគេហទំព័រ Facebook Page “Cambodia Securities Exchange- CSX” និងតាមរយៈសៀវភៅនៅសាកលវិទ្យាល័យ វ៉ាន់ដា ដែលបានបង្រៀនពាក់ព័ន្ធនឹងការជួញដូរមូលបត្រផ្ទាល់តែម្តង។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

### ១. សម្រាប់ផ្ទាល់ខ្លួន

- ការវិនិយោគ និងបង្កើនទ្រព្យសម្បត្តិ៖ អ្នកវិនិយោគអាចទិញឯកសារហិរញ្ញវត្ថុ ដូចជា មូលបត្រ ដើម្បីទទួលបានប្រាក់ចំណេញក្នុងអនាគត។
- ការចូលរួមក្នុងទីផ្សារហិរញ្ញវត្ថុ៖ បុគ្គលអាចចូលរួមជាអ្នកវិនិយោគបែបសាធារណៈ ដែលជួយសម្រួលការប្រមូលផ្តុំថវិកាដែលមានគោលដៅ។
- ការពង្រឹងចំណេះដឹងហិរញ្ញវត្ថុ៖ ការចូលរួមជាមួយទីផ្សារមូលបត្រជួយឱ្យបុគ្គលស្វែងយល់ពីសេដ្ឋកិច្ច និងការគ្រប់គ្រងហិរញ្ញវត្ថុផ្ទាល់ខ្លួន។

### ២. សម្រាប់ស្ថាប័ន

- ប្រភពផ្នែកហិរញ្ញវត្ថុ៖ ស្ថាប័នអាចចេញមូលបត្រដើម្បីរកប្រាក់ចូលសម្រាប់ការវិនិយោគ ឬការអភិវឌ្ឍគម្រោង។
- ការកែលម្អភាពជឿជាក់ពីសាធារណៈ: ការចេញមូលបត្រនៅទីផ្សារសាធារណៈបង្ហាញពីភាពមានទំនួលខុសត្រូវ និងភាពស្ថិរភាពរបស់ស្ថាប័ននោះ។
- ការចូលរួមក្នុងសេដ្ឋកិច្ចសេរី៖ ជួយស្ថាប័នចូលរួមក្នុងប្រព័ន្ធហិរញ្ញវត្ថុប្រកបដោយសុវត្ថិភាព និងតម្លាភាព។

### ៣. សម្រាប់សង្គមជាតិ

- បង្កើនភាពសកម្មផ្នែកសេដ្ឋកិច្ច៖ ការជួញដូរមូលបត្រជាសាធារណៈជួយឱ្យមានចលនា និងភាពសកម្មក្នុងប្រព័ន្ធហិរញ្ញវត្ថុជាតិ។
- ជំរុញការអភិវឌ្ឍសេដ្ឋកិច្ច៖ ដោយមានការប្រមូលប្រាក់វិនិយោគពីសាធារណៈ នេះអាចប្រើសម្រាប់គម្រោងអភិវឌ្ឍដូចជា វារីអគ្គិសនី ស្ថាបនាកសិកម្ម ឬ ផ្លូវ។
- ពង្រឹងភាពជឿជាក់លើប្រព័ន្ធហិរញ្ញវត្ថុជាតិ៖ បើប្រព័ន្ធនេះដំណើរការបានល្អ នឹងធ្វើឱ្យសង្គមទូលំទូលាយមានទំនុកចិត្តលើរដ្ឋ និងវិស័យឯកជន។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធនៃរបាយការណ៍នេះមានលក្ខណៈដូចខាងក្រោម៖

**ជំពូកទី ១ (សេចក្តីផ្តើម)** បង្ហាញអំពីលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហា គោលបំណង ដែនកំណត់ វិសាលភាព វិធីសាស្ត្រ និងសារៈសំខាន់នៃការស្រាវជ្រាវ។

**ជំពូកទី ២ (រំលឹកទ្រឹស្តី)** បង្ហាញពីនិយមន័យ ប្រវត្តិទូទៅដែលពាក់ព័ន្ធ និងទ្រឹស្តីរបស់អ្នកប្រាជ្ញដែលពាក់ព័ន្ធនឹងការសិក្សាស្រាវជ្រាវ ។

**ជំពូកទី៣ (ដំណើរការជួញដូរមូលបត្រជាសាធារណៈនៅកម្ពុជា)** ស្វែងយល់អំពីដំណើរការនៃការជួញដូរមូលបត្រនៅកម្ពុជារបស់ផ្សារមូលបត្រកម្ពុជា (ផ.ម.ក) ទើបក្រុមយើងខ្ញុំសម្រេចធ្វើការស្រាវជ្រាវតែក្នុងអំឡុងឆ្នាំ២០២៣ តែប៉ុណ្ណោះ។

**ជំពូកទី៤ (ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ)** បង្ហាញពីការវិភាគ និងធ្វើការស្វែងយល់ពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ប្រធានបទដែលពាក់ព័ន្ធ។

**ជំពូកទី៥ (សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍)** សន្និដ្ឋានទៅលើចំណុចទាំងអស់ដែលនៅក្នុងអត្ថបទ និងផ្តល់អនុសាសន៍ទៅលើចំណុចដែលមានកង្វះខាតដើម្បីធ្វើការកែលម្អ ។

# ជំពូកទី២
# ការជួញដូរមូលបត្រជាសាធារណៈ

## ២.១ លក្ខណៈទូទៅនៃការជួញដូរមូលបត្រ

### ២.១.១ និយមន័យមូលបត្រ

**មូលបត្រ** គឺជាកិច្ចសន្យាហិរញ្ញវត្ថុដែលអាចជួញដូរបាន ដែលកិច្ចសន្យានេះ បញ្ជាក់ពីភាពជាម្ចាស់កម្មសិទ្ធ ឬម្ចាស់បំណុលលើក្រុមហ៊ុនមួយហើយយើងក៏អាចធ្វើការជួញដូរមូលបត្រនេះបានដែរ។ មូលបត្រមាន ៣ប្រភេទ គឺភាគហ៊ុន សញ្ញាប័ណ្ណ និងឧបករណ៍និស្សន្ទ[1]។

### ២.១.២ ប្រវត្តិនៃមូលបត្រ

ប្រវត្តិសាស្ត្រនៃមូលបត្រ គឺវែង និងស្មុគស្មាញ ដោយមានឫសគល់តាំងពីសតវត្សរ៍ទី១២ និងវិវត្តន៍ដើម្បីរួមបញ្ចូលទីផ្សារភាគហ៊ុនទំនើប និងបទប្បញ្ញត្តិមូលបត្រៈ

**ក.ការជួញដូរដំបូង**

នៅសតវត្សទី១២ និងទី១៣ ឈ្មួញកណ្តាលបានជួញដូរទំនិញនិងបំណុល។ នៅទីក្រុង Venice អ្នកឱ្យខ្ចីនឹងយកក្រដាស់បិតជាមួយព័ត៌មានអំពីបញ្ហាសម្រាប់លក់ស្រដៀងទៅនឹងឈ្មួញកណ្តាលទំនើប។

ផ្សារហ៊ុនដំបូងគេនៅសហរដ្ឋអាមេរិកត្រូវបានបង្កើតឡើងនៅទីក្រុង Philadelphia ក្នុងឆ្នាំ១៧៩១។ ផ្សារហ៊ុនញូវយ៉កត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៧៩២ ហើយបានយកឈ្មោះបច្ចុប្បន្នរបស់ខ្លួននៅឆ្នាំ១៨៦៣។

**ខ.បទប្បញ្ញត្តិមូលបត្រ**

**"ច្បាប់មេឃខៀវ"** ដំបូងត្រូវបានអនុម័តនៅក្នុងរដ្ឋ Kansas ក្នុងឆ្នាំ១៩១១ ដែលទាមទារឱ្យមានការចុះបញ្ជីមូលបត្រ និងអ្នកលក់របស់ពួកគេ។ ច្បាប់នេះជាការឆ្លើយតបទៅនឹងអ្នកវិនិយោគដែលត្រូវបានអ្នកលក់យកចំណេញពីការលក់ផលប្រយោជន៍គ្មានតម្លៃក្នុងក្រុមហ៊ុន និងរ៉ែមាស។

**គ.ច្បាប់មូលបត្រឆ្នាំ១៩៣៣**

នៅមុនច្បាប់នេះ មូលបត្រគឺស្ថិតនៅក្រោមបទប្បញ្ញត្តិរបស់រដ្ឋតែប៉ុណ្ណោះ ហើយឈ្មួញកណ្តាលអាចសន្យាថានឹងផ្តល់ផលចំណេញខ្ពស់ជាមួយនឹងព័ត៌មានពាក់ព័ន្ធតិចតួច។ ផ្សារមូលបត្រកម្ពុជា ត្រូវបានដាក់បញ្ចូលក្នុងឆ្នាំ២០១០ ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា (MEF) មានភាគហ៊ុន ៥៥% នៃដើមទុនចុះបញ្ជី ហើយក្រុមហ៊ុនប្តូរប្រាក់កូរ៉េ (KRX) កាន់កាប់ ៤៥% ដែលនៅសល់[2]។

### ២.១.៣ លក្ខណៈនៃមូលបត្រ

**មូលបត្រ** គឺជាកិច្ចសន្យាហិរញ្ញវត្ថុដែលអាចជួញដូរបាន។ កិច្ចសន្យានេះបញ្ជាក់ពីកម្មសិទ្ធិបំណុល ឬសិទ្ធិ/កាតព្វកិច្ចក្នុងការទិញ/លក់ ជាដើម។ ក្នុងនោះមូលបត្រចែកចេញជាពីរ គឺមូលបត្រកម្មសិទ្ធិ និងមូលបត្របំណុល។

---

[1] Liked in. Sok Sotheara. (2027, August 14). *មូលបត្រ(Securities).* Retrieved 2025, June 12 from https://www.linkedin.com/pulse/មលបតរsecurities-sok-sotheara

[2] AMS. CSX. (2021, June 8). *ស្វែងយល់អំពីមូលបត្រកម្មសិទ្ធិ និងមូលបត្របំណុល.).* Retrieved 2025, June 12 from https://economy.ams.com.kh/28431

### ក. មូលបត្រកម្មសិទ្ធិ

**ផលិតផល ទ្រព្យកម្មសិទ្ធិ** គឺជាមូលបត្រដែលបាន បោះផ្សាយដោយក្រុមហ៊ុនសាធារណៈ ដើម្បីគៀងគរមូលនិធិពីសាធារណៈជន។ វារួមបញ្ចូលទាំងភាគហ៊ុនរបស់ក្រុមហ៊ុន ដែលតំណាងឱ្យភាពជាម្ចាស់របស់វិនិយោគិននៅក្នុងក្រុមហ៊ុននោះ។ ភាពជាម្ចាស់នៃទ្រព្យកម្មសិទ្ធិនឹងផ្តល់សិទ្ធិដល់ភាគហ៊ុនិក នូវចំណែកនៃប្រាក់ចំណេញរបស់ក្រុមហ៊ុនតាមរយៈភាគលាភ។ ភាគហ៊ុនិក គឺជាម្ចាស់នៃអាជីវកម្មព្រមទាំងចូលរួមទទួលនូវការចែករំលែកភាពជោគជ័យឬបរាជ័យនៃអាជីវកម្មរបស់ក្រុមហ៊ុន។ លទ្ធផលដំណើរការអាជីវកម្ម របស់ក្រុមហ៊ុនចុះបញ្ជីជាធម្មតាអាចវាយតម្លៃ បានតាមរយៈភាគលាភដែលភាគហ៊ុនិកបានទទួល និងតាមរយៈថ្លៃភាគហ៊ុនដែលបានដាក់ថ្លៃនៅលើទីផ្សារ។មានមូលបត្រកម្មសិទ្ធិ ២ ប្រភេទដែលអាចដាក់ជួញដូរនៅលើផ្សារមូលបត្រកម្ពុជា(ផ.ម.ក.)៖

- **ភាគហ៊ុនធម្មតា** ៖ គឺជាភាគហ៊ុនដែលមានការលើកទឹកចិត្តដោយផ្ទាល់ដល់អ្នកកាន់កាប់ភាគហ៊ុនតាមរយៈភាគលាភដែលទទួលបានពីប្រាក់ចំណេញរបស់ក្រុមហ៊ុនការចំណេញលើមូលធន និងសិទ្ធិក្នុងការទិញភាគហ៊ុនថ្មីរបស់ ក្រុមហ៊ុននៅពេលដែលក្រុមហ៊ុនសម្រេចក្នុងការបង្កើនដើមទុនចុះបញ្ជី របស់ខ្លួន។
- **ភាគហ៊ុនបុរិមា** ៖ ភាគហ៊ុនបុរិមាក៏ជាផ្នែកមួយនៃទ្រព្យកម្មសិទ្ធិផងដែរ។ ភាពខុសគ្នារវាងភាគហ៊ុនបុរិមានិង ភាគហ៊ុនធម្មតាគឺ អ្នកកាន់កាប់ភាគហ៊ុនបុរិមានឹងមានសិទ្ធិទទួលបានមូលនិធិ ឬ ប្រាក់ចំណេញរបស់ក្រុមហ៊ុនមុនភាគហ៊ុនធម្មតា។

### ខ.មូលបត្របំណុល

**មូលបត្របំណុល** គឺជាប្រភេទមូលបត្របំណុល ដែលតំណាងឱ្យកិច្ចសន្យាខ្ចីប្រាក់រវាងបុគ្គលបោះផ្សាយមូលបត្របំណុល (រួមមានសាជីវកម្ម សហគ្រាសរដ្ឋ ឬរាជរដ្ឋាភិបាល) និងវិនិយោគិន (ម្ចាស់មូលបត្របំណុល)។ តាមរយៈកិច្ចសន្យានេះ បុគ្គលបោះផ្សាយមូលបត្របំណុលមានកាតព្វកិច្ចបង់ឱ្យវិនិយោគិននូវទឹកប្រាក់ជាក់លាក់មួយជាទៀងទាត់ដែលហៅថា "គូប៉ុង" ឬ "ការប្រាក់" (លើកលែងសម្រាប់សញ្ញាប័ណ្ណគ្មានការប្រាក់) ព្រមទាំងបង់ប្រាក់ដើមនៅពេលដែលសញ្ញាបណ្ណនោះដល់កាលកំណត់សងដែលហៅថា "ឥណប្រទិទាន"។ ជំនួសឱ្យការខ្ចីប្រាក់ពីធនាគារ ក្រុមហ៊ុន ឬ អង្គភាពមួយអាចបោះផ្សាយសញ្ញាបណ្ណទៅឱ្យវិនិយោគិនដោយផ្ទាល់ នៅពេលដែលក្រុមហ៊ុននោះត្រូវការសាច់ប្រាក់ដើម្បីផ្តល់ហិរញ្ញប្បទានដល់គម្រោងថ្មីៗ បន្តប្រតិបត្តិការក្រុមហ៊ុន ឬដើម្បីទូទាត់បំណុល។ លក្ខណៈខុសគ្នាចម្បងមួយរវាងភាគហ៊ុន និងសញ្ញាបណ្ណ គឺថាសញ្ញាបណ្ណតំណាងឱ្យភាពជាម្ចាស់បំណុល រីឯភាគហ៊ុនតំណាងឱ្យភាពជាម្ចាស់កម្មសិទ្ធិនៃក្រុមហ៊ុនមួយ។ ថ្លៃភាគហ៊ុនអាចកើនឡើងយ៉ាងឆាប់រហ័ស ប្រសិនបើក្រុមហ៊ុននោះមានការរីកចម្រើន និងមានប្រាក់ចំណេញច្រើន។ ផ្ទុយទៅវិញ សញ្ញាបណ្ណធ្វើការទូទាត់តែការប្រាក់ដែលបានកំណត់ជាមុន ហើយថ្លៃរបស់វាប្រែប្រួលនៅក្នុងដែនដែលកំណត់ដោយអត្រាការប្រាក់ ពោលគឺមិនមែនកំណត់ដោយប្រាក់ចំណេញរបស់ក្រុមហ៊ុននោះឡើយ។

### ២.១.៤. ទ្រឹស្តីពាក់ព័ន្ធ

### ក. លក្ខណៈនៃមូលបត្របំណុល

**សញ្ញាបណ្ណ (Bond)** គឺប្រភេទមូលបត្របំណុលដែលមានលក្ខណៈដូចខាងក្រោម៖

.មានតម្លៃចារឹក(Face Value ឬ Par Value) ជាទូទៅ 1,000$/Par។

.គឺជារបៀបខ្ចីប្រាក់ដ៏ទំនើប

.មានការប្រាក់ (Interest)

.គឺជាបំណុលរយៈពេលវែង (Long Term Liabilities)

.ម្ចាស់មូលបត្របំណុលគឺជា ម្ចាស់បំណុល

.ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ SECC

.ត្រូវបានទិញចូលមកវិញក្នុងថ្ងៃកំណត់សង (Maturity Date)

.សញ្ញាបណ្ណបោះលក់ក្នុងទីផ្សារមូលបត្រ (Stock Exchange/Stock Market)

.មូលបត្របំណុលស្ថិតក្រោមការគ្រប់គ្រងរបស់ Security and Exchange Commission of Cambodia (SECC)។

### ខ. ចំណាត់ថ្នាក់នៃសញ្ញាបណ្ណ (Classification of Bond)

Bond ត្រូវបានបែងចែកជា ៣ ផ្នែក

- អង្គភាពបោះលក់(Issuing entities )

-Industrial Bond: ក្រុមហ៊ុនសាជីវកម្មជាអ្នកបោះលក់។

-Municipal Bond: រដ្ឋបោះលក់។

**មានរបស់បញ្ចាំ**(Collateral)

-Mortgage Bond (Secured Bond): មានរបស់បញ្ចាំ។

-Debenture bond (Unsecured Bond ):គ្មានរបស់បញ្ចាំ។

**គោលបំណងនៃការបោះលក់**(Purpose of issue)

-ទិញមូលបត្របំណុល: ជាការទូទាត់ពេញលេញ ឬជាផ្នែកសម្រាប់អចលនទ្រព្យ។

-ការបង្វិលសងមូលបត្របំណុល: ដើម្បីចូលនិវត្តន៍នូវមូលបត្របំណុលដែលមានស្រាប់។

-មូលបត្របំណុលរួម: ដើម្បីជំនួសបញ្ហាដែលមានស្រាប់មួយចំនួន។

### គ. គុណសម្បត្តិនៃការបោះលក់សញ្ញាបណ្ណ

-មូលបត្របំណុលមិនប៉ះពាល់ដល់ការគ្រប់គ្រងម្ចាស់ភាគហ៊ុនទេ។

-ការប្រាក់លើមូលបត្របំណុលត្រូវបាន។

-សញ្ញាប័ណ្ណអាចបង្កើនការត្រឡប់ទៅភាគហ៊ុនចំណេញ នាំឱ្យកើនទុន។

-ការកាត់ពន្ធការប្រាក់

-ម្ចាស់បំណុល មិនចូលរួមក្នុងកំណើន ប្រាក់ចំណូលរបស់ក្រុមហ៊ុនទេ ពេលក្រុមហ៊ុនសាជីវកម្មចំណេញច្រើននោះ ម្ចាស់បំណុលគ្មានសិទ្ធិបង្ខំឱ្យក្រុមហ៊ុនសាជីវកម្មចែកភាគលាភទេតែ Preferred shareholder និង Common shareholder មានសិទ្ធិ។

-Bond is repaid in cheaper dollar during inflation (**real rate + Inflation + Risk premium**)

-It may be safe guard the company future finance: ដល់ថ្ងៃកំណត់ទើប Bondholder យកមកលក់ឱ្យវិញនាំឱ្យគ្មាន Risk កើតឡើងគឺ Corp.គេបានត្រៀមខ្លួនមុនជាស្រេច។

### ឃ. គុណវិបត្តិនៃការបោះលក់សញ្ញាបណ្ណ

-Bond required payment of both periodic interest and par value at maturities.

-Bond can decrease equity

-Interest charge must be met ការប្រាក់ត្រូវតែបង់

-In debenture may place stringent restriction ចំពោះ bond ដែលគ្មានរបស់បញ្ចាំនោះ SECC គេមានសិទ្ធិតាមដានលើក្រុមហ៊ុនសាជីវកម្មយកលុយនោះទៅធ្វើអ្វីខុសគោលបំណងកាលពីស្នើសុំបោះសញ្ញាបណ្ណនៅ SECC[3]។

## ២.២ ដំណើរការជួញដូរមូលបត្រជាសាធារណៈនៅកម្ពុជា

### ២.២.១ និយមន័យការជួញដូរ

**ការជួញដូរ** ជាសកម្មភាពប្ដូរផលិតផល ឬ សេវាកម្មរវាងមនុស្ស ឬ ស្ថាប័ន ដោយមានគោលបំណងទទួលបានផលចំណេញ។ វាអាចជាការទិញ–លក់ ឬ ការប្ដូរផលិតផលដោយផ្ទាល់ (barter)។

### ២.២.២ ដំណើរនៃការការជួញដូរ

#### ក. ប្រភេទនៃការជួញដូរ

- ការជួញដូរខាងក្នុង (Domestic trade): កើតមាននៅក្នុងប្រទេសតែមួយ
- ការជួញដូរអន្តរជាតិ (International trade): កើតមានក្នុងប្រទេស និងក្រៅប្រទេស

#### ខ. ការជួញដូរនៅក្នុងវិស័យហិរញ្ញវត្ថុ

- ការជួញដូរមូលបត្រ (Bond trading)
- ការជួញដូរភាគហ៊ុន (Stock trading)
- ការជួញដូរទូរបរទេស (Forex trading)
- ការជួញដូរដើមទុនឌីជីថល (Cryptocurrency trading)

#### គ. ឧបករណ៍នៃការជួញដូរបច្ចុប្បន្ន

- តាមអ៊ិនធើណិត (online platforms)
- តាមផ្សារភាគហ៊ុន (stock exchanges)
- តាមបណ្ដាញសង្គម (Facebook Marketplace, Telegram groups ។ល[4]។

## ២.៣ វិស័យមូលបត្រនៅកម្ពុជាមានអត្ថប្រយោជន៍ដល់សេដ្ឋកិច្ច

### ២.៣.១ និយមន័យសេដ្ឋកិច្ច

[3] វិទ្យាស្ថាន វ៉ាន់ដា. (២០២៣). *ការគ្រប់គ្រងហិរញ្ញវត្ថុ.* បោះពុម្ពលើកទី៥ ទំព័រទី៣៨-៣៩

[4] E-Library INABA. Paul R. Krugman, Maurice Obstfeld, Marc J. Melitz. (2018). *International Economics Theory and Policy*. (11th edition). Retrieved 2025, June 12 from, https://opaclib.inaba.ac.id/index.php?p=show_detail&id=1374&keywords=

**សេដ្ឋកិច្ច** ជាវិទ្យាសាស្ត្រសិក្សាស្រាវជ្រាវរកវិធីដើម្បីដោះស្រាយបញ្ហាការប្រើប្រាស់ឱ្យចំទីកន្លែងចំគោលដៅនិងចំណាយពេលវេលាមានប្រសិទ្ធិភាពនូវការប្រើប្រាស់ធនធានសេដ្ឋកិច្ចដែលមានកំណ(Limited Resources)ក្នុងទិសដៅបំពេញឱ្យបានតម្រូវការសង្គមមនុស្សដែលគ្មានដែនកំណត់ (unlimited want)[5]។

**២.៣.២ ប្រវត្តិសេដ្ឋកិច្ច**

**ប្រវត្តិសាស្ត្រសេដ្ឋកិច្ច** សាខានៃប្រវត្តិសាស្ត្រទាក់ទងនឹងប្រវត្តិសាស្ត្រ និងការអភិវឌ្ឍនៃប្រព័ន្ធសេដ្ឋកិច្ច និងកាន់តែទូលំទូលាយជាមួយនឹងការស៊ើបអង្កេតលើទិដ្ឋភាពសេដ្ឋកិច្ច នៃសង្គមប្រវត្តិសាស្ត្រ។ ការសិក្សាប្រវត្តិសាស្ត្រ និងសេដ្ឋកិច្ចធ្លាប់មានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ។ សេដ្ឋវិទូ និងទស្សនវិទូជនជាតិស្កុតឡេន អាដាម ស្ម៊ីធ (១៧២៣-៩០) សេដ្ឋវិទូ និងប្រជាសាស្ត្រអង់គ្លេស ថូម៉ាស ម៉ាលធូស (១៧៦៦-១៨៣៤) និងសេដ្ឋវិទូ និងទស្សនវិទូអាឡឺម៉ង់ លោក ខាល ម៉ាក្ស (១៨១៨-៨៣) គឺជាអ្នកសេដ្ឋកិច្ចនយោបាយទាំងអស់ដែលបានបញ្ចូលទិន្នន័យប្រវត្តិសាស្ត្ររបស់ពួកគេទៅក្នុងការវិភាគប្រវត្តិសាស្ត្រ។ សាលាប្រវត្តិសាស្ត្រសេដ្ឋកិច្ចដែលព្យាយាមស្វែងយល់ពីស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសមួយក្នុងបរិបទនៃបទពិសោធន៍ប្រវត្តិសាស្ត្រសរុបរបស់ខ្លួន បានបង្កើតនៅប្រទេសអាឡឺម៉ង់នៅចុងសតវត្សទី១៩ ហើយត្រូវបានផ្សារភ្ជាប់ជាមួយនឹងតួលេខដូចជា Gustav von Schmoller (១៨៣៨-១៩១៧)។ ប្រតិកម្មប្រឆាំងនឹងគោលលទ្ធិពាណិជ្ជកម្មសេរីរបស់អ្នកសេដ្ឋកិច្ចអង់គ្លេស (ដែលនឹងរារាំងអាឡឺម៉ង់ពីការការពារឧស្សាហកម្មរបស់ខ្លួនរហូតដល់ពួកគេមានកម្លាំងគ្រប់គ្រាន់ដើម្បីប្រកួតប្រជែង) សេដ្ឋវិទូប្រវត្តិសាស្ត្របានអះអាងថាមិនមានច្បាប់សេដ្ឋកិច្ចជាសកលត្រឹមត្រូវទេ ហើយថាប្រទេសនីមួយៗគួរតែកំណត់ផ្លូវសេដ្ឋកិច្ចផ្ទាល់ខ្លួន។

ការចាប់អារម្មណ៍ស្រដៀងគ្នានៅក្នុងការអភិវឌ្ឍន៍ ប្រវត្តិសាស្ត្រត្រូវបានបង្ហាញដោយអ្នកសេដ្ឋកិច្ចតាមស្ថាប័នដូចជា ទេពកោសល្យដ៏ចម្លែក Thorstein Veblen (១៨៥៧-១៩២៩)។ សមាគមប្រវត្តិសាស្ត្រអាមេរិក និងសមាគមសេដ្ឋកិច្ចអាមេរិកត្រូវបានបង្កើតឡើងរួមគ្នា ហើយមិនបានបំបែកចេញពីគ្នាអស់រយៈពេលជាច្រើនឆ្នាំ។ ជាការពិត វាជារឿងធម្មតានៅក្នុងមហាវិទ្យាល័យអាមេរិកសម្រាប់អ្នកប្រវត្តិសាស្ត្រ និងអ្នកសេដ្ឋកិច្ចនៅក្នុងនាយកដ្ឋានតែមួយ។ទោះយ៉ាងណាក៏ដោយចាប់ពីវេននៃសតវត្សទី២០ មុខវិជ្ជាទាំងពីរបានបន្តផ្លូវខុសគ្នាយ៉ាងខ្លាំង។ ខណៈពេលដែលអ្នកសេដ្ឋកិច្ចបានបង្កើតគំរូគណិតវិទ្យាដែលកាន់តែល្អិតល្អន់អ្នកប្រវត្តិសាស្ត្រនៅតែជាប់គាំងនៅក្នុងព័ត៌មានលម្អិតដ៏រញ៉េរញ៉ៃនៃពិភពលោក។

ខណៈពេលដែលការបែងចែករវាងវិញ្ញាសានេះបានកើតឡើង ការស្រាវជ្រាវដ៏ល្អជាច្រើនត្រូវបានធ្វើឡើងលើការងារនៃសេដ្ឋកិច្ចបុរេឧស្សាហកម្ម និងលើសំណួរថាហេតុអ្វីបានជា serfdom ត្រូវបានណែនាំនៅក្នុងប្រទេសប៉ូឡូញ និងរុស្ស៊ី។ នៅក្នុងប្រទេសមួយចំនួន សន្ទស្សន៍តម្លៃនៃការរស់នៅដែលគ្របដណ្តប់ជាច្រើនសតវត្សត្រូវបានគណនា។ទោះបីជាការប៉ាន់ប្រមាណទាំងនេះមិនល្អឥតខ្ចោះ (ដូចដែលពួកគេនៅតែមាន) ពួកគេបានបំភ្លឺសំណួរដ៏ល្បីល្បាញដូចជាមូលហេតុនៃបដិវត្តន៍បារាំង(១៧៨៧-៩៩) និងស្ថានភាពនៃវណ្ណៈកម្មករក្នុងអំឡុងពេលបដិវត្តន៍ឧស្សាហកម្មនៅប្រទេសអង់គ្លេស។ វិទូជនជាតិបារាំងCamille-Ernest Labrousse (១៨៩៥-១៩៨៨) បានបង្ហាញថានៅប្រទេសបារាំងក្នុងអំឡុងពេលពី ឆ្នាំ១៧៧៨ ដល់ឆ្នាំ ១៧៨៩ វិបត្តិសេដ្ឋកិច្ចដ៏យូរត្រូវបានធ្វើឱ្យកាន់តែធ្ងន់ធ្ងរឡើងដោយតម្លៃនំប៉័ងខ្ពស់។ អ្នកជឿលើបុព្វហេតុ "កាន់តែស៊ីជម្រៅ" នៃបដិវត្តន៍បានចាត់ទុកការភ្ជាប់នេះគ្រាន់តែជាការបង្កហេតុប៉ុណ្ណោះ ប៉ុន្តែចាប់តាំងពីការ

[5] វិទ្យាស្ថាន វ៉ាន់ដា. (២០១២). *មីក្រូសេដ្ឋកិច្ច.* បោះពុម្ពលើកទី៣ ទំព័រទី៤

រំខានជាច្រើនក្នុងឆ្នាំដំបូងនៃបដិវត្តន៍ គឺជាកុបកម្មនំប៉័ងដែលប្រែទៅជាអំពើហិង្សាផ្នែកនយោបាយវាពិបាកក្នុងការជៀសវាង ការសន្និដ្ឋានថាប្រវត្តិសាស្ត្រនៃរយៈពេលនឹងមានភាពខុសគ្នាខ្លាំងនៅក្រោមលក្ខខណ្ឌសេដ្ឋកិច្ចផ្សេងៗគ្នា។

ប្រវត្តិសាស្ត្រសេដ្ឋកិច្ចនៅចក្រភពអង់គ្លេស តែងតែទទួលឥទ្ធិពលពីការពិតដែលថា វាជាប្រទេសដំបូងគេដែលឆ្លងកាត់បដិវត្តន៍ឧស្សាហកម្ម។ បន្ទាប់ពីសង្គ្រាមលោកលើកទី២ អ្នករៀបចំផែនការសេដ្ឋកិច្ចបានមើលទៅចក្រភពអង់គ្លេស សម្រាប់ឧទាហរណ៍អំពីរបៀបដែលប្រទេសក្នុងប្រទេសកំពុងអភិវឌ្ឍន៍អាចសម្រេចបានការផ្លាស់ប្តូរដូចគ្នា។ សេដ្ឋវិទូ និងទ្រឹស្តីនយោបាយជនជាតិអាមេរិក លោក Walt Whitman Rostow (១៩១៦-២០០៣) នៅក្នុងដំណាក់កាលនៃកំណើនសេដ្ឋកិច្ច (១៩៦០) បានព្យាយាមទ្រឹស្តីទូទៅអំពីរបៀបដែលសេដ្ឋកិច្ចធ្វើឧស្សាហកម្ម។ គំរូប្រាំមួយដំណាក់កាលរបស់គាត់មិនទទួលបានការទទួលយកជាទូទៅទេ ប៉ុន្តែគាត់បានលើកឡើងពីបញ្ហានៃការអភិវឌ្ឍន៍សេដ្ឋកិច្ចរយៈពេលវែង ដែលដឹកនាំអ្នកសេដ្ឋកិច្ចមួយចំនួនយ៉ាងហោចណាស់ឆ្ពោះទៅរកប្រវត្តិសាស្ត្រ។

សំណើរដែលថាបដិវត្តន៍ឧស្សាហកម្ម គឺជារឿងល្អត្រូវបានគេរក្សាជាសាកលដោយអ្នកប្រវត្តិសាស្ត្រដែលមានការអាណិតអាសូរចំពោះមូលធននិយម។ ម្យ៉ាងវិញទៀត អ្នកប្រវត្តិសាស្ត្រសង្គមនិយមបានវិនិច្ឆ័យវាដោយភាពស្រពិចស្រពិល។ សម្រាប់ពួកម៉ាក្សនិយមគ្រិស្តអូស្សូដក់ មានតែប្រទេសឧស្សាហូបនីយកម្មទេដែលបង្កើតក្រុមអ្នកសេដ្ឋកិច្ចខ្លាំងគ្រប់គ្រាន់ដើម្បីដកហូតមធ្យោបាយផលិតកម្ម ហើយអំណាចផលិតភាពដ៏ធំសម្បើមនៃសង្គមឧស្សាហកម្មនឹងក្លាយជាមូលដ្ឋាននៃ "នគរដ៏បរិបូរណ៍" ក្រោមរបបកុម្មុយនីស្ត។ ទន្ទឹមនឹងនោះ ពួកគេបានសង្កត់ធ្ងន់លើវិធីបំពានដែលឧស្សាហូបនីយកម្មត្រូវបានអនុវត្ត និងការឈឺចាប់របស់កម្មករ។ ដោយសារតែភ័ស្តុតាងជាច្រើនសម្រាប់ទុក្ខលំបាករបស់កម្មករ គឺពិតជារឿងអនាធិបតេយ្យអ្នកប្រវត្តិសាស្ត្រសេដ្ឋកិច្ចមួយចំនួនបានព្យាយាមកំណត់ថាតើកម្រិតជីវភាពរបស់ពួកគេពិតជាបានធ្លាក់ចុះ ឬយ៉ាងណាទោះបីជាអត្រាប្រាក់ឈ្នួលត្រូវបានគេដឹងក៏ដោយ កម្មករឧស្សាហ៍កម្មត្រូវបានបញ្ឈប់ជាញឹកញាប់ ដូច្នេះប្រាក់ចំណូលប្រចាំឆ្នាំរបស់ពួកគេមិនមែនជាផលបូកសាមញ្ញនៃប្រាក់ឈ្នួលមធ្យមរបស់ពួកគេនោះទេ។ ទោះ បីជាមានការលំបាកនៃការគណនាដ៏ចម្រូងចម្រាសដែលជៀសមិនរួចក៏ដោយ វាហាក់ដូចជាការពិតដែលថាកម្រិតជីវភាពរបស់កម្មករយ៉ាងហោចណាស់មិនធ្លាក់ចុះទេ ហើយថែមទាំងអាចមានភាពប្រសើរឡើងបន្តិចមុនឆ្នាំ ១៨៥០។ ការសន្និដ្ឋាននេះ មិនបានដោះស្រាយបញ្ហានៃការឈឺចាប់របស់ពួកគេទេ ចាប់តាំងពីកម្មករក៏ស៊ូទ្រាំនឹងការខាតបង់សេដ្ឋកិច្ចផងដែរ។ បញ្ហានេះ នៅតែបន្តជាក្តីបារម្ភសម្រាប់អ្នកប្រវត្តិសាស្ត្រសង្គម និងសេដ្ឋកិច្ច។

### ២.៣.៣ ប្រព័ន្ធនៃសេដ្ឋកិច្ចសំខាន់ៗ

#### ក. សេដ្ឋកិច្ចបុរាណ (Traditional economic)

គឺជាប្រព័ន្ធសេដ្ឋកិច្ចមួយដែលរាល់ការសម្រេចចិត្ត ប្រើប្រាស់ធនធានរបស់សង្គមពឹងផ្អែកលើមូលដ្ឋានប្រពៃណី ទំនៀមទំលាប់ សហគមន៍ គ្រួសារ ឬ សាសនា ហើយការជួញដូរមិនប្រើប្រាស់ប្រាក់កាសទេ។

**ខ. សេដ្ឋកិច្ចផែនការ ឬប្រព័ន្ធសេដ្ឋកិច្ចផែនការ(Command/Planned economic)**

គឺជាប្រព័ន្ធសេដ្ឋកិច្ចមួយដែលរាល់ការសម្រេចចិត្ត ប្រើប្រាស់ធនធានរបស់សង្គមដោយ អាជ្ញាធរកណ្ដាល(រដ្ឋាភិបាល) ជាអ្នកកំណត់ដំណើរការប្រព្រឹត្តិទៅនៃសេដ្ឋកិច្ច និង ជាអ្នកធ្វើ សេចក្ដីសំរេចចិត្ត ថាតើត្រូវផលិតអ្វី? ផលិតយ៉ាងដូចម្ដេច? បែងចែក យ៉ាងដូចម្ដេច? នរណាជាអ្នកទទួលយក?

**គ. សេដ្ឋកិច្ចទីផ្សារ (Market economic)**

គឺជាប្រព័ន្ធសេដ្ឋកិច្ចមួយដែលរាល់ការសម្រេចចិត្ត ប្រើប្រាស់ធនធានរបស់សង្គមដោយពឹងផ្អែកលើសិទ្ធិនៃ ទ្រព្យសម្បត្តិឯកជន និង ទីផ្សារ ដែលនៅក្នុងនោះនីតិបុគ្គលទាំងឡាយជាអ្នកធ្វើសេចក្ដីសម្រេចចិត្តថាតើត្រូវផលិតអ្វី? ផលិតយ៉ាងដូចម្ដេច? ផលិតប៉ុន្មាន? ផលិតពេលណា?

**ឃ. សេដ្ឋកិច្ចចំរុះ (Mixed economic)**

គឺជាប្រព័ន្ធសេដ្ឋកិច្ចមួយដែលរាល់ការសម្រេចចិត្ត ប្រើប្រាស់ធនធានរបស់សង្គម ដែលរដ្ឋនិងឯកជនជាអ្នកដឹកនាំសេដ្ឋកិច្ចដែលបង្ហាញពីចរិតលក្ខណៈ នៃសេដ្ឋកិច្ចទីផ្សារ និងសេដ្ឋកិច្ចផែនការ។

**ង. សេដ្ឋកិច្ចថ្មី (New economy)**

គឺជាប្រព័ន្ធសេដ្ឋកិច្ចមួយដែលមានមូលដ្ឋានលើបច្ចេក វិទ្យាថ្មីសំខាន់ពីរគឺកុំព្យូទ័រនិងទូរគមនាគមន៍។ ឧទាហរណ៍ អ៊ិនធើណិត អ៊ីមែល (e-mail) រដ្ឋាភិបាលអេឡិចត្រូនិក(e-government) និងរូបិយវត្ថុអេឡិចត្រូនិក (e-money)[6]។

[6] វិទ្យាស្ថាន វ៉ាន់ដា. (២០១២). *មីក្រូសេដ្ឋកិច្ច*. បោះពុម្ពលើកទី៣ ទំព័រទី៤

# ជំពូកទី៣

# ដំណើរការជួញដូរមូលបត្រជាសាធារណៈនៅកម្ពុជា

## ៣.១ ស្ថានភាពទូទៅរបស់ទីផ្សារមូលបត្រ

### ៣.១.១ ប្រវត្តិរបស់ទីផ្សារមូលបត្រ

ដើម្បីសម្រេចឱ្យបាននៅកាអភិវឌ្ឍប្រទេសកម្ពុជា ដោយឈរលើគោលការនៅក្នុងការជម្រុញកំណើនសេដ្ឋកិច្ចតាមរយៈលំហូមូលធន ការវិនិយោគ និងការវិភាជន៍ជាថ្មីនៅមូលធនតាមរយៈយន្តការទីផ្សារមូលបត្រនៅខែវិច្ឆិកា ឆ្នាំ២០០៦ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជានិងក្រុមហ៊ុនផ្សារមូលបត្រនៅកូរ៉េបានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ ស្តីអំពី <ការអភិវឌ្ឍមូលបត្រនៅកម្ពុជា>។ ដោយផ្អែកលើអនុស្សរណៈ យោគយល់គ្នានេះ សម្តេចអគ្គសេនាបតីតេជោហ៊ុនសែននាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានប្រកាសបើកឲដំណើរការ គម្រោងបង្កើតទីផ្សារមូលបត្រកម្ពុជានៅ ខែកញ្ញា ឆ្នាំ២០០៧។ នៅឆ្នាំ២០០៨ អនុស្សរណៈយោគយល់មួយទៀតស្តីអំពី <ការបង្កើតផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា> ត្រូវបានចុះហត្ថលេខាដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។ នៅខែមីនា ឆ្នាំ២០០៩ រដ្ឋាភិបាលកម្ពុជាដែលដំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េបានចុះកិច្ចព្រមព្រៀងធ្វើជាក្រុមហ៊ុនចំរុះគ្នា (Joint Venture) បានបង្កើតផ្សារមូលបត្រ <ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា> ស្របតាមច្បាប់ស្តីពីសហគ្រាសសាធារណៈ។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានចុះដើម្បីសម្រេចឱ្យបាននៅការអភិវឌ្ឍប្រទេសកម្ពុជា ដោយឈរលើគោលការនៅក្នុងការជម្រុញកំណើនសេដ្ឋកិច្ចតាមរយៈលំហូមូលធនការវិនិយោគ និងការវិភាជន៍ជាថ្មីនៅមូលធនតាមរយៈយន្តការទីផ្សារមូលបត្រនៅ ខែវិច្ឆិកា ឆ្នាំ២០០៦ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជានិងក្រុមហ៊ុនផ្សារមូលបត្រនៅកូរ៉េបានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ ស្តីអំពី<ការអភិវឌ្ឍមនៅកម្ពុជា>។ ដោយផ្អែកលើអនុស្សរណៈ យោគយល់គ្នានេះ សម្តេចអគ្គសេនាបតីតេជោហ៊ុនសែននាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានប្រកាសបើកឲដំណើរការគម្រោងបង្កើតទីផ្សារមូលបត្រកម្ពុជានៅខែកញ្ញា ឆ្នាំ២០០៧។ នៅឆ្នាំ២០០៨ អនុស្សរណៈយោគយល់មួយទៀតស្តីអំពី <ការបង្កើតផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា> ត្រូវបានចុះហត្ថលេខាដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។ នៅខែ មីនា ឆ្នាំ២០០៩ រដ្ឋាភិបាលកម្ពុជាដែលដំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េបានចុះកិច្ចព្រមព្រៀងធ្វើជាក្រុមហ៊ុនចំរុះគ្នា (Joint Venture) បានបង្កើតផ្សារមូលបត្រ<ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា> ស្របតាមច្បាប់ស្តីពីសហគ្រាសសាធារណៈ។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានចុះបញ្ជីពាណិជ្ជកម្មនៅ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១០។ ស្របតាមកិច្ចព្រមព្រៀងក្រុមហ៊ុនចំរុះ(Joint Venture) ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកានកាប់ភាគហ៊ុនចំនួន៥៥% នៃភាគហ៊ុនសរុបក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ហើយផ្សារមូលបត្រកូរ៉េកាន់កាប់ភាគហ៊ុនចំនួន៤៥% នៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាដែរ។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបាន អាជ្ញាទទួលបណ្ណជាប្រតិបត្តិករផ្សារមូលបត្រ ប្រតិបត្តិករប្រពន្ធ័ផាត់ទាត់និងទូទាត់មូលបត្រព្រមទាំងប្រតិបត្តិកររក្សាទុកមូលបត្រពីគណៈកម្មការមូលបត្រកម្ពុជា (គ. ម. ក ) ស្របតាមច្បាប់ស្តីពីកាបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

សរុបរួមប្រវត្តិរបស់ទីផ្សារមូលបត្រ

-២០ វិច្ឆិកា ២០០៦ អនុស្សរណៈយោគយល់ស្តីពីការអភិវឌ្ឍផ្សារមូលបត្រនៃព្រះរាជាណាចក្រកម្ពុជា។

-០៦ កញ្ញា ២០០៧ ការដាក់ឲដំណើរការគម្រោងបង្កើតផ្សារមូលបត្រកម្ពុជា។

-២១ មករា ២០០៨ អនុស្សរណៈយោគយល់ស្តីកាបង្កើតផ្សារមូលបត្រនៃព្រះរាជាណាចក្រកម្ពុជា។

-២៣ មីនា ២០០៩ កិច្ចព្រមព្រៀងស្តីពី<<ក្រុមហ៊ុនចម្រុះ>>រវាងរដ្ឋាភិបាលកម្ពុជាតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ ២៣ កុម្ភៈ ២០០៩ ចុះបញ្ជីពាណិជ្ជកម្ម។

-២៨ កុម្ភៈ ២០១០ ការទទួលបណ្ណជាប្រតិបត្តិករផ្សារមូលបត្រ ប្រតិបត្តិករប្រពន្ធ័ផាត់ទាត់និងទូទាត់មូលបត្រព្រមទាំងប្រតិបត្តិកររក្សាទុកមូលបត្រពីគណៈកម្មការមូលបត្រកម្ពុជា (គ. ម. ក)។

-១៨ មេសា ២០១២ ពិធីប្រកាសបើកការជួញដូរមូលបត្រនៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

-១៨ មេសា ២០១២ ពិធីប្រកាសបើកការជួញដូរមូលបត្រនៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

### ៣.១.២ ស្ថានភាពទូទៅរបស់ផ្សារមូលបត្រ

ស្ទើរតែពេញមួយសតវត្សរ៍ទី ២១ ប្រទេសកម្ពុជាមានការរីចម្រើនខាងផ្នែកសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ ដោយបានផ្លាស់ប្តូរពីប្រទេសដែលមានភាពចលាចលនយោបាយទៅជាប្រទេស ដែលមានកំណើនសេដ្ឋកិច្ចលឿនបំផុតមួយនៅលើពិភពលោក។ ប្រទេសកម្ពុជាបានក្លាយទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាបក្នុងឆ្នាំ ២០១៥ ដែលភាគច្រើនជាលទ្ធផលនៃកំណែទម្រង់ទីផ្សារសេរី ការដាក់ចេញនូវគោលនយោបាយនិងបទបញ្ញត្តិសំខាន់ៗ ការកែលម្អបរិយាកាសធុរៈកិច្ច និងការបង្កើនតួនាទីរបស់ខ្លួន ក្នុងពាណិជ្ជកម្មអន្តរជាតិតាមរយៈជាប្រទេសសមាជិករបស់អាស៊ាន។ លើកាវិនិយោគមូលបត្រត្រូវបានហាមឃាត់នៅពេលចេញមូលបត្រតាមរយៈទីភ្នាក់ងារឯកជន។ទោះជាតយ៉ាងណាក្តីវាមិនមានន័យថា គណៈកម្មការមូលបត្រមិនអនុញ្ញាតិឱ្យទីភ្នាក់ងារឯកជនចេញមូលបត្រឡើយវាអាចធ្វើទៅបានឱ្យតែគោរពតាមបទបញ្ញាកំណត់ ទីភ្នាក់ងារមូលបត្រឯកជនក្នុងវិស័យមូលបត្រនៅកម្ពុជា។ គណៈកម្មការមូបត្រត្រូវផ្តល់សិទ្ធឱ្យចេញ ឬ ជួញដូរមូលបត្រសាធារណៈស្របតាមលក្ខខណ្ឌ ដែលបានបង្កើតឡើងលើកំណែរទម្រង់ថ្មីៗនេះទៅលើទីផ្សារប្តូរប្រាក់បានធ្វើឱ្យមានភាពប្រសើរឡើងនូវទីផ្សារមូលបត្រ និងការពង្រឹងបានលើការវិនិយោគ ព្រមទាំងការពង្រឹងវិសកម្មភាពសេដ្ឋកិច្ច។

### ៣.១.៣ បេសកកម្ម និង ទស្សនវិស័យទីផ្សារមូលបត្រ

- ដើម្បីបង្កើនបាននូវបរិយាកាសជួញដូរមូលបត្រដែលមានអំណោយ ផលដល់អ្នកវិនិយោគទាំងក្រៅនិងក្នុងប្រទេស។
- ដើម្បីងាយស្រួលក្នុងការគៀគរប្រមូលទុននៅកម្ពុជាសម្រាប់ពង្រីកសហគ្រាស។
- បង្កើតនូវផលិតផលនិងសេវាកម្មដ៏ទំនើបជាច្រើនប្រភេទ សម្រាប់អ្នកចូលរួមទីផ្សារទាំងអស់។

### ៣.១.៤ រចនាសម្ព័ន្ធគ្រប់គ្រងនៃទីផ្សារមូលបត្រកម្ពុជា

**រចនាសម្ព័ន្ធគ្រប់គ្រងនៃទីផ្សារមូលបត្រកម្ពុជា**

ឧបសម្ព័ន្ធគ្រប់គ្រងបទបញ្ញាផ្ទៃក្នុងសម្រាប់ការគ្រប់គ្រង ផ. ម. ក




## ៣.២ .ដំណើរការជួញដូរមូលបត្រជាសាធារណៈនៅកម្ពុជា

នៅក្នុងដំណើរការជួញដូរមូលបត្រជាសាធារណៈនៅកម្ពុជាមានតួអង្គទាំង៧

### ៣.២.១ គណៈកម្មការមូលបត្រកម្ពុជា (Securities and Exchange Commission of Cambodia)

ផ្សារមូលបត្រដែលអាចដំណើរការទៅបាន លុះត្រាតែមានច្បាប់ និងបទបញ្ញត្តិផ្សេងៗ ដើម្បីគ្រប់គ្រង និង ត្រួតពិនិត្យទៅលើវិស័យទីផ្សារមូលបត្រទាំងមូល។ ច្បាប់ និងបទបញ្ញត្តិទាំងនេះ ត្រូវបានកំណត់ដោយគណៈកម្មការមូលបត្រតាមបណ្តាប្រទេសនីមួយៗ។ ចំណែកឯកម្ពុជាក៏មានគណៈកម្មការមូលបត្រដែរ ដែលមានឈ្មោះហៅថា**គណៈកម្មការមូលបត្រកម្ពុជា**(គ.ម.ក) ហើយមានតួនាទីកំណត់ច្បាប់ និងបទបញ្ញត្តិនានា ដើម្បីគ្រប់គ្រងវិស័យមូលបត្រកម្ពុជា ក្នុងគោលបំណងចូលរួមចំណែកដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និង សង្គម តាមរយៈការគៀងគរមូលធនពីសាធារណជន ឬ អ្នកវិនិយោគមូលបត្រ ដើម្បីឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុ សម្រាប់ការវិនិយោគនៅកម្ពុជា។

#### ក. ប្រវត្តិរបស់គណៈកម្មការមូលបត្រកម្ពុជា

គណៈកម្មការមូលបត្រកម្ពុជាត្រូវបានបង្កើតឡើងតាមព្រះរាជក្រមលេខនស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧។ ដោយសារតែភាពមិនទាន់រឹងមាំនៃបទពិសោធន៍ច្បាប់ និងពិសេសដោយសារឥទ្ធិពលនៃវិបត្តិសេដ្ឋកិច្ចពិភពលោកផងទើបផ្សារមូលបត្រកម្ពុជាត្រូវបានពន្យារពេលរហូតដល់ ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២។

ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ គឺជាថ្ងៃចាប់ផ្តើមគោះជួងបើកផ្សារហ៊ុនដំបូងបំផុតនៅកម្ពុជា ដោយក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា(CSX)និងបានដាក់ឱ្យដេញថ្លៃនូវហ៊ុនកម្មសិទ្ធរបស់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។

## ខ.រចនាសម្ពន្ធគ្រប់គ្រង

គ.ម.ក មានរចនាសម្ពន្ធចាត់តាំងដូចខាងក្រោម ៖




## គ.ចក្ខុវិស័យ

គណៈកម្មការមូលត្រកម្ពុជាហៅកាត់ថា គ.ម.ក ត្រូវបានបង្កើតឡើងក្រោយពីច្បាប់មូលបត្ររដ្ឋនិងច្បាប់ស្ដីពីការបោះផ្សាយនិងជួញដូរមូលបត្រមហាជនបានអនុម័តរួច។ គ.ម.កមានគោលដៅគ្រប់គ្រងវិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងចូលរួមចំណែកដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងសង្គម តាមរយៈការគៀងគរមូលធនពី សាធារណជន ឬអ្នកវិនិយោគមូលបត្រ ដើម្បីឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុសម្រាប់ការវិនិយោគនៅកម្ពុជា។

## ឃ.បេសកកម្ម

-បង្កើត និងរក្សាឱ្យមានទំនុកចិត្តពីអ្នកវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការពារសិទ្ធិស្របច្បាប់របស់អ្នកវិនិយោគ និងធានាឱ្យមានការបោះផ្សាយ រួមទាំងធ្វើឱ្យការជួញដូរមូលបត្រប្រកបដោយសណ្ដាប់ធ្នាប់ និងត្រឹមត្រូវ។

-លើកកម្ពស់ការគ្រប់គ្រងទីផ្សារមូលបត្រឱ្យមានប្រសិទ្ធភាពនិង ជំរុញការអភិវឌ្ឍន៍ទីផ្សារនេះឱ្យមានសណ្ដាប់ធ្នាប់ និងរបៀបរៀបរយ។

-ជំរុញឱ្យមានភាពសម្បូរបែបនៃឧបករណ៍សញ្ជ័យ តាមរយៈការទិញមូលបត្រ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត( សញ្ជ័យ saving tools )។

-ជំរុញឱ្យមានការធ្វើវិនិយោគទុនពីបរទេស និងចូលរួមក្នុងទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

-ជួយសម្រួលដល់ការផ្ទេរឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**៣.២.២ ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតចុះបញ្ជី(PLD Listed)**

ក្នុងវិស័យមូលបត្រ ដែលអាចដំណើរការទៅបាន ត្រូវតែមានអ្នកបោះលក់មូលបត្រ។ នៅប្រទេសកម្ពុជាអ្នកបោះលក់មូលបត្រ មានតែក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។ ប្រភេទក្រុមហ៊ុនទាំងអស់ដែលមានបំណងចង់បោះផ្សាយលក់មូលបត្រជាសាធារណៈ ត្រូវកម្លាយខ្លួនជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត(Public Limited Company)ជាមុនសិន។ ដូច្នេះ ក្នុងមេរៀននេះនឹងសិក្សាលម្អិតអំពីក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតចុះបញ្ជី។

**១ ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតចុះបញ្ជី**

**ក-កម្លាយខ្លួនទៅជាក្រុមហ៊ុនចុះបញ្ជី**

ទោះជាក្រុមហ៊ុនបែបណាក៏ដោយ ដើម្បីចូលផ្សារហ៊ុនបានក្រុមហ៊ុនទាំងនោះ ត្រូវកម្លាយខ្លួនទៅជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតចុះបញ្ជី ដែលធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជាជាដាច់ខាត។

**ខ-ភាគហ៊ុនិក(Shareholders)**

ភាគហ៊ុនិក គឺជាម្ចាស់ហ៊ុនដែលគ្មានតួនាទីដឹកនាំគ្រប់គ្រងអ្វីទាំងអស់។ សិទ្ធិជាមូលដ្ឋានរបស់ភាគហ៊ុនិក ដែលបានកំណត់ដោយច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មមិនត្រូវបានដកហូត ឬ រឹតត្បិតដោយការចែងនៅក្នុងលក្ខន្តិកៈក្រុមហ៊ុនឡើយ។ ភាគហ៊ុនិកត្រូវទទួលបាននូវការគោរព និងការពារសិទ្ធិទាំងនេះពីក្រុមប្រឹក្សាក្រុមហ៊ុន។

**គ-ក្រុមប្រឹក្សាភិបាល(Board of Directors)**

ក្រុមប្រឹក្សាភិបាល សំដៅដល់បុគ្គលមួយក្រុមដែលត្រូវបានបោះឆ្នោតជ្រើសរើសដោយភាគហ៊ុនិក ហើយមានសិទ្ធិអំណាចអនុវត្តភារកិច្ចដូចមានចែងក្នុងលក្ខន្តិកៈក្រុមហ៊ុន។

**ឃ-គណៈកម្មាធិការសវនកម្ម(Audit Committee)**

គណៈកម្មាធិការសវនកម្មត្រូវមានសមាជិកយ៉ាងតិច០៣រូប ដែលអភិបាលឯករាជ្យជាប្រធាន។ យ៉ាងហោចណាស់សមាជិក០១ត្រូវមានឯកទេស និងបទពិសោធន៍ខាងហិរញ្ញវត្ថុ និងសមាជិកដទៃទៀតត្រូវមានការយល់ដឹងផ្នែកគណនេយ្យនិងហិរញ្ញវត្ថុ។

គណៈកម្មាធិការនេះ មានតួនាទី និងភារកិច្ចដែលត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល។ ដែលរាប់បញ្ចូលនូវតួនាទី និងភារកិច្ចជាអាទិ៍ ដូចខាងក្រោម៖

-ពិនិត្យរបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ

-ពិនិត្យការគ្រប់គ្រងផ្ទៃក្នុង

-ពិនិត្យការធ្វើសវនកម្មផ្ទៃក្នុង

-ពិនិត្យការធ្វើសវនកម្មខាងក្រៅ

-រាយការណ៍ទៅឱ្យក្រុមប្រឹក្សាភិបាលពីសកម្មភាពរបស់ខ្លួន។

**ង-គណៈកម្មាធិការគ្រប់គ្រងហានិភ័យ(Risk Management Committee)**

ករណីទ្រព្យសកម្មរបស់ក្រុមហ៊ុន ដែលត្រូវបោះផ្សាយលក់មូលបត្រជាសាធារណៈមានចំនួនចាប់ពី ២០០.០០០.០០០.០០០(ពីររយពាន់លាន)រៀល ត្រូវបង្កើតគណៈកម្មាធិការគ្រប់គ្រងហានិភ័យនេះដាច់ចេញពីគណៈកម្មាធិការសវនកម្ម។ គណៈកម្មាធិការនេះ ត្រូវមានសមាជិកយ៉ាងតិច ០៣(បី)រូប ដែលមានអភិបាលឯករាជ្យជាប្រធាន។ យ៉ាងហោចណាស់សមាជិក ០១(រូប) ត្រូវមានឯកទេស និងបទពិសោធន៍ខាងហិរញ្ញវត្ថុ ឬគ្រប់គ្រងហានិភ័យ។ ចំពោះក្រុមហ៊ុនត្រូវបោះផ្សាយលក់មូលបត្រជាសាធារណៈដែលមានទ្រព្យសកម្មតិចជាង ២០០.០០០.០០០.០០០(ពីររយពាន់លាន)រៀល តួនាទីរបស់គណៈកម្មាធិការគ្រប់គ្រងហានិភ័យអាចអនុវត្តដោយគណៈកម្មាធិកាសវនកម្ម។

**ច-គណៈកម្មាធិការតែងតាំង(Nomination Committee)**

សំដៅដល់គណៈកម្មាធិការឯកទេសមួយរបស់ក្រុមប្រឹក្សាភិបាលដែលទទួលខុសត្រូវក្នុង ការពិនិត្យឡើងវិញនិងវាយតម្លៃអំពីគុណវុឌ្ឍិបុគ្គលទាំងឡាយ ដែលជាបេក្ខភាពសម្រាប់ការតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុនដែលទទួលបានការយល់ព្រមពីក្រុមប្រឹក្សាភិបាល។

**ឆ-បុគ្គលិកជាន់ខ្ពស់(Senior Officers)**

សំដៅដល់បុគ្គលទាំងឡាយណាដែលមានមុខតំណែងចាប់ពីប្រធាននាយកដ្ឋាន និងរហូតដល់អគ្គនាយកដ្ឋាន ប្រធានសវនកម្មផ្ទៃក្នុងលេខាធិការក្រុមហ៊ុន និងអ្នកដែលមានមុខតំណែងសំខាន់ផ្សេងទៀតក្នុងក្រុមហ៊ុន។

**ជ-សវនករផ្ទៃក្រៅ(External Auditor)**

កំណត់សំដៅដល់សវនកររបស់ក្រុមហ៊ុនគណនេយ្យករជំនាញ ដែលជាសមាជិកសកម្មរបស់វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា(Kicpaa) ហើយដែលទទួលស្គាល់ដោយ គ.ម.ក ។

**ឈ-សវនករផ្ទៃក្នុង(Internal Auditor)**

សំដៅដល់សវនកររបស់ ក្រុមហ៊ុនដែលទទួលប្រាក់ខែពីក្រុមហ៊ុនមានតួនាទីតាមដានឆែកឆេរប្រមូលភ័ស្តុតាង រួចវាយតម្លៃទៅលើអ្នកគ្រប់គ្រងពីការអនុវត្តន៍ការងារស្របតាមគោលនយោបាយ ឬមិនស្រប? ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈត្រូវមានសវនកម្មផ្ទៃក្នុង។សវនកម្មផ្ទៃក្នុងត្រូវរាការណ៍ដោយផ្ទាល់ជូនគណៈកម្មាធិការសវនកម្ម និងត្រូវមានការទទួលខុសត្រូវ និងកាតព្វកិច្ចដូចខាងក្រោម៖

១.បង្ហាញពីការវាយតម្លៃដែលអាចទទួលយកបាននិងមានតុល្យភាពអំពីប្រសិទ្ធភាពស្ថានភាព និងការរំពឹងទុករបស់សក្រុមហ៊ុន។

២.រាយការណ៍អំពីដំណើរការធុរកិច្ចរបស់ក្រុមហ៊ុន និងបញ្ហាជាសក្តានុពល។

៣.រក្សាភាពរឹងមាំនូវប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដើម្បីការពារ ផលប្រយោជន៍របស់ភាគហ៊ុនិក និងការវិនិយោគរបស់ភាគីពាក់ព័ន្ធនឹងទ្រព្យសកម្មរបស់ក្រុមហ៊ុន។

៤.អនុវត្តន៍ការស៊ើបអង្កេតសវកម្មផ្ទៃក្នុងគ្របដណ្តប់ទៅលើការវាយតម្លៃពីភាពសមស្រប និង ប្រសិទ្ធភាពនៃអភិបាលកិច្ចប្រតិបត្តការនិងប្រព័ន្ធព័ត៌មាន ដោយរាប់បញ្ចូលទាំងការ ការពារទ្រព្យសកម្ម និងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិ។

៥.ផ្តល់ឱ្យគណៈកម្មាធិការសវនកម្ម និងបុគ្គលិកជាន់ខ្ពស់នូវរបាយការណ៍ប្រចាំឆ្នាំស្តីអំពី សកម្មភាពពាក់ព័ន្ធនឹងផែនការសវនកម្ម និងយុទ្ធសាស្ត្រដែលទទួលការយល់ព្រមពីគណៈកម្មាធិការសវនកម្ម។ របាយការណ៍ប្រចាំឆ្នាំនេះត្រូវរាប់បញ្ចូលទាំងនិងការប្រឈមហានិភ័យបញ្ហាត្រួតពិនិត្យបញ្ហាអភិបាលកិច្ចសាជីវកម្ម និងបញ្ហាដទៃទៀត ដែលស្នើដោយក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់។ គណៈកម្មាធិការសវនកម្មត្រូវតែផ្តល់របាយការណ៍ឱ្យភាគហ៊ុនិក របស់ក្រុមហ៊ុនដែលជាផ្នែកមួយនៃរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាភិបាល។

៦.គណៈកម្មាធិការសវនកម្មត្រូវធានាថាសវនករផ្ទៃក្នុងមានសិទ្ធិទទួលបានព័ត៌មានទាំងស្រុងអំពីការកំណត់ត្រាទ្រព្យ និងបុគ្គលិកពាក់ព័ន្ធនឹងសកម្មភាពសវនកម្ម និងធានាថាសវនកម្មផ្ទៃក្នុងមិនទទួលរងការជ្រៀតជ្រែកក្នុងការកំណត់ពីវិសាលភាពនៃការត្រួតពិនិត្យ ការអនុវត្តការងារ និងការបញ្ជូនលទ្ធផលនៃការត្រួតពិនិត្យ។

**៣-អ្នកពាក់ព័ន្ធ**

អ្នកផ្តល់ឥណទាន(Creditors) បុគ្គលដែលមានទំនាក់ទំនងផលប្រយោជន៍ ឬមានកិច្ចសន្យាជាមួយក្រុមហ៊ុន ត្រូវបានចាត់ទុកជាភាគីពាក់ព័ន្ធរបស់ក្រុមហ៊ុន(Related Party)។ រាល់ភាគីពាក់ព័ន្ធទាំងអស់របស់ក្រុមហ៊ុនត្រូវទទួលបាននូវការការពារសិទ្ធ។ ក្រុមហ៊ុនត្រូវធានាការការពារសិទ្ធិដល់ភាគីពាក់ព័ន្ធជាអាទិ៍ដូចខាងក្រោម៖

១.ត្រូវមានគោលនយោបាយគ្រប់គ្រងយុទ្ធសាស្ត្រច្បាស់លាស់ ដើម្បីគាំទ្រ ការពារសិទ្ធិរបស់ភាគីពាក់ព័ន្ធ។

២.ត្រូវធានាការអនុវត្តតាមច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា។

៣.មិនត្រូវធ្វេសប្រហែសចំពោះការទទួលខុសត្រូវសង្គម ជាការការពារអ្នកប្រើប្រាស់ និងការការពារបរិស្ថាន។

៤.ទទួលស្គាល់និងការពារសិទ្ធិដាច់ចេញពីគ្នានៅពេលដែលបុគ្គលជា ភាគីពាក់ព័ន្ធនិងជាភាគហ៊ុន។

ក្រុមហ៊ុនត្រូវផ្តល់ឱ្យភាគីពាក់ព័ន្ធដូចជា អ្នកផ្តល់ឥណទាន(Creditors) និងនិយោជិត(Employee) នូវព័ត៌មានពាក់ព័ន្ធដែលចាំបាច់ ដើម្បីតាមដាននូវដំណើរការរបស់ក្រុមហ៊ុន ព្រមទាំងត្រូវការពារសិទ្ធិរបស់ពួកគេ។

**ជ-ការបង្ហាញព័ត៌មានពេញលេញ(Full disclosure)**

ក្រុមហ៊ុនត្រូវបង្ហាញព័ត៌មានទាន់ពេល និងមានប្រសិទ្ធភាព ដែលតម្រូវដោយច្បាប់ និងបទបញ្ញត្តិ និងព័ត៌មានផ្សេងទៀត ដែលអាចមានផលប៉ះពាល់ដល់ការសម្រេចចិត្តរបស់ភាគហ៊ុនិក និងភាគីពាក់ព័ន្ធដទៃទៀត(Stakeholders)។ព័ត៌មានសំខាន់ៗដែលទាក់ទងនឹងអភិបាលកិច្ចសាជីវកម្មដែលក្រុមហ៊ុន បង្ហាញរួមមាន ៖

១.សមាសភាពក្រុមប្រឹក្សាភិបាល រួមទាំងអភិបាលប្រតិបត្តិ អភិបាលមិនប្រតិបត្តិ អភិបាលឯករាជ្យ រចនាសម្ពន្ធក្រុមប្រឹក្សាអភិបាល រចនាសម្ពន្ធគ្រប់គ្រង គោលនយោបាយលើកទឹកចិត្តគោលនយោបាយពាក់ព័ន្ធទំនាស់ផលប្រយោជន៍ និងក្រមសីលធម៌របស់អភិបាល និងបុគ្គលិកជាន់ខ្ពស់(Senior Officers)។

២.សិទ្ធិតួនាទី និងភារកិច្ចសកម្មភាពនៃគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាភិបាល។

៣.សកម្មភាពរបស់អភិបាលម្នាក់ៗ និងក្រុមប្រឹក្សាភិបាល។

៤.ដំណើរការប្រព័ន្ធបោះឆ្នោតត្រួតពិនិត្យ ករណីទទួលបានកាអនុម័តពីភាគហ៊ុនិក។

**ឋ-ស្តង់ដាបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា**

ក្រុមហ៊ុនបោះផ្សាយមូលបត្រលក់ ត្រូវតែធ្វើរបាយការណ៍ហិរញ្ញវត្ថុឱ្យស្របតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ដូចមានកំណត់ក្នុងប្រកាសលេខ ០៦៨ សហវ/ប្រក របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះថ្ងៃទី ០៨ ខែមករា ឆ្នាំ២០០៩ ស្តីពីការដាក់ឱ្យប្រើស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា( ស.រ.ហ.ក )។

**៣.២.៣ ផ្សារមូលបត្រកម្ពុជា(Cambodia Securities Exchange)**

ផ្សារមូលបត្រ គឺជាកន្លែងទិញលក់មូលបត្រ ដូចជាបណ្ណភាគហ៊ុន(Stock) បណ្ណបំណុល(Bond) និងឧបករណ៍ហិរញ្ញវត្ថុ(OtherSecurities)ផ្សេងៗទៀត។ ផ្សារមូលបត្រដើរតួយ៉ាងសំខាន់ក្នុងវិស័យសេដ្ឋកិច្ចរបស់ប្រទេសនីមួយៗ ដោយអនុញ្ញាតឱ្យក្រុមហ៊ុនសាជីវកម្ម សហគ្រាសសាធារណៈ និងរដ្ឋាភិបាលអាចប្រមូលទុនដោយផ្ទាល់ពីសាធារណជន មកប្រើប្រាស់ដើម្បីពង្រីកអាជីវកម្ម ឬអភិវឌ្ឍហេដ្ឋារចនាសម្ពន្ធជាដើម។ ម្យ៉ាងវិញទៀត អ្នកដែលមានប្រាក់សល់ពីការចំណាយ មានជម្រើសក្នុងការវិនិយោគរបស់ខ្លួន ឬធ្វើការសន្សំនៅក្នុងទីផ្សារមូលបត្របន្ថែមទៀត។ នៅប្រទេសកម្ពុជា ក៏ទើបតែបានដាក់ឱ្យដំណើរការផ្សារមូលបត្ររបស់ខ្លួនជាលើកដំបូង ដែលមានឈ្មោះថា «ផ្សារមូលបត្រកម្ពុជា» ដោយមានការចូលរួមគ្នារវាងរដ្ឋាភិបាលកម្ពុជា ( ៥៥% ) និងផ្សារមូលបត្រកូរ៉េ( ៤៥% )។

**១. ទិដ្ឋភាពទូទៅនៃទីផ្សារមូលបត្រ**

ផ្សារមូលបត្រ ជាផ្នែកយ៉ាងសំខាន់មួយក្នុងប្រព័ន្ធហិរញ្ញវត្ថុជាតិ ដើម្បីគៀគរប្រភពហិរញ្ញវត្ថុផ្សេងៗមកធ្វើការអភិវឌ្ឍន៍សេដ្ឋកិច្ចឱ្យមានល្បឿនកាន់តែខ្ពស់។ វត្តមាននៃទីផ្សារមូលបត្រនឹងផ្តល់ ជម្រើសដល់ការវិនិយោគថ្មីៗបន្ថែមទៀត ក្រៅពីការកំចីពីធនាគារ។ ផ្សារមូលបត្រក៏ជួយដល់អ្នកសល់ប្រាក់ទំនេរ ឱ្យចេះប្រើប្រាស់សាច់ប្រាក់កាន់តែមានប្រសិទ្ធិភាពខ្ពស់។ ទីផ្សារមូលបត្រទាំងមូលដែលអាចដំណើរការទៅបាននេះ គឺស្ថិតក្រោមច្បាប់ និងបទបញ្ញត្តិនានា ដែលរៀបចំនិង អនុម័តដោយគណៈកម្មាធិកាមូលបត្រនៃប្រទេសនីមួយយៗ។ ជាទូទៅច្បាប់ និងបទបញ្ញត្តិនានានៅក្នុងវិស័យមូលបត្រ គឺមានគោលបំណងជួយពង្រឹង និងធានាថាប្រព័ន្ធទីផ្សារមូលបត្រមានភាពត្រឹមត្រូវមានប្រសិទ្ធិភាព។ រាល់ប្រតិបត្តិការទាំងអស់ដែលពាក់ព័ន្ធនៅក្នុង វិស័យមូលបត្រទាំងមូល គឺស្ថិតក្រោមបទបញ្ញត្តិយ៉ាងពិសេសដោយតម្រូវឱ្យមានការដាក់បង្ហាញព័ត៌មាននានាជាសាធារណៈកាត់បន្ថយការក្លែងបន្លំដែលផ្ទុយពីច្បាប់ និងបទបញ្ញត្តិនានានៃទីផ្សារមូលបត្រឱ្យរួមតូចក្នុងកម្រឹតអសារវន្ត។ ច្បាប់ និងបទបញ្ញត្តិមូលបត្រត្រូវបានគេអនុវត្ត ដើម្បីគ្រប់គ្រងរាល់ព័ត៌មានទាំងអស់នៅលើទីផ្សារព្រមទាំងដំណើរការជួញដូរមូលបត្រ។ ការធ្វើដូច្នេះ គឺធ្វើឱ្យវិនិយោគិនម្នាក់ៗអាចទទួលបានព័ត៌មានដូចគ្នានៅក្នុងពេលតែមួយ ហើយមានឱកាសដូចគ្នាក្នុងការជួញដូរមូលបត្រ។ ច្បាប់ និងបទបញ្ញត្តិទាំងអស់នេះក៏បានកំណត់ឱ្យពិនិត្យតាមដានផងដែរ នូវអាកប្បកិរិយាអ្នកចូលរួមទីផ្សារទាំងអស់ រួមទាំងការផាកពិន័យនានាផងដែរ ។

## ២. ទស្សនវិស័យ និងបេសកកម្ម

-ដើម្បីងាយស្រួលគៀគរប្រមូលទុននៅកម្ពុជាសម្រាប់ពង្រីកសហគ្រាស

-ដើម្បីបង្កើតបរិយាកាសជួញដូរមូលបត្រដែលអំណោយផលដល់វិនិយោគិនក្នុងនិងក្រៅប្រទេស

-ដើម្បីបង្កើតផលិតផល និងសេវាកម្មដ៏ទំនើបច្រើនប្រភេទ សម្រាប់អ្នកចូលរួមទីផ្សារទាំងអស់។

## ៣. រចនាសម្ព័ន្ធគ្រប់គ្រងនៃទីផ្សារមូលបត្រកម្ពុជា

### ក. រចនាសម្ព័ន្ធគ្រប់គ្រងនៃទីផ្សារមូលបត្រកម្ពុជា




១-នាយកដ្ឋានចុះបញ្ជីនិងផ្តល់ព័ត៌មាន(Listed & Disclosure Department)

២-នាយកដ្ឋានប្រតិបត្តិការទីផ្សារមូលបត្រ(Market Operations Department)

៣-នាយកដ្ឋានផាត់ទាត់និងទូទាត់មូលបត្រ(Securities Clearing & Settlement Department)

៤-នាយកដ្ឋានប្រតិបត្តិការរក្សាទុកមូលបត្រ(Securities Depository Department)

៥-នាយកដ្ឋានព័ត៌មានវិទ្យា(IT Department)

៦-នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ(Administration & Finance Department)

### ខ. ក្រុមប្រឹក្សាភិបាល




ក្រុមប្រឹក្សាភិបាលនៃផ.ម.ក. រួមមានសមាជិកចំនួន ៧រូប ដោយរាប់បញ្ចូលទាំងប្រធានក្រុមប្រឹក្សាភិបាល អនុប្រធានក្រុមប្រឹក្សាភិបាល(ដែលជាអគ្គនាយករងផងដែរ) និងអគ្គនាយក។ប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយកជាតំណាងរបស់រាជរដ្ឋាភិបាលកម្ពុជា។ចំណែកឯអនុប្រធានក្រុមប្រឹក្សាភិបាល គឺជាតំណាងរបស់ក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។

សមាជិកចំនួន ៤រូបផ្សេងទៀតគឺជាអភិបាលមិនអចិន្ត្រៃយ៍ ដោយក្នុងនោះ២រូបត្រូវបានតែងតាំងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង២រូបទៀតត្រូវបានតែងតាំងដោយក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។

**៣.២.៤ ក្រុមហ៊ុនមូលបត្រ(Securities Company)**

ក្រុមហ៊ុនមូលបត្រ គឺសំដៅដល់នីតិបុគ្គល ឬជាក្រុមហ៊ុន ដែលទទួលបានអាជ្ញាបណ្ណពី **គ.ម.ក** ធ្វើជាក្រុមហ៊ុនមូលបត្រ។ហើយក្រុមហ៊ុនមូលបត្ររួមមាន៖ក្រុមហ៊ុនធានាទិញមូលបត្រ(Securities Underwriter)ក្រុមហ៊ុនពាណិជ្ជករមូលបត្រ(Securities Dealer),ក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ(Securities Broker) និងមិនរួមបញ្ចូលក្រុមហ៊ុនផ្តល់ប្រឹក្សាមូលបត្រ(Investment Advisor/Consultant)ទេ។ ដូច្នេះក្នុងមេរៀននេះយើងនឹងសិក្សាលម្អិតអំពីក្រុមហ៊ុនមូលបត្របត្រ និងភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រនេះតែម្តង។តើក្រុមហ៊ុនមូលបត្រនិងភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រមានតួនាទី ឬ សកម្មភាពក្នុងទីផ្សារមូលបត្រយ៉ាងដូចម្តេច?

**១ តួនាទី និងភារកិច្ចក្រុមហ៊ុនមូលបត្រ**

**១.១ សមាសភាពក្រុមហ៊ុនមូលបត្រ**

ក្រុមហ៊ុនមូលបត្រ គឺសំដៅដល់ក្រុមហ៊ុនធានាទិញមូលបត្រ(Securities Underwriter) ក្រុមហ៊ុនពាណិជ្ជករមូលបត្រ(Securities Dealer) និងក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ(Securities Broker)។

**ក. ក្រុមហ៊ុនធានាទិញមូលបត្រ(Securities Underwriter)** រួមមាន ៖

-ផ្តល់ប្រឹក្សាសំខាន់លើ ការបោះផ្សាយលក់មូលត្រជាសាធារណៈដូចការដាក់តម្លៃមូលបត្រ(pricing) ការកំណត់ទំហំទឹកប្រាក់ (issue amount) និងចំនួនមូលបត្រ(number of securities to be issued) នៃសំណើបោះផ្សាយលក់មូលបត្រនិងការកំណត់ពេលវេលានៃការបោះផ្សាយលក់មូលបត្រជាសាធាណៈ(distribution timeline)ជាដើម។

-ទិញមូលបត្រទាំងអស់ឬមួយផ្នែកពីក្រុមហ៊ុនបោះផ្សាយមូលបត្រក្នុងគោលដៅចែកចាយឬលក់បន្ត

-ទិញមូលបត្រដែលលក់មិនអស់នៅក្នុងដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈក្នុងគោលដៅធានានូវភាពជោគជ័យនៃការបោះផ្សាយ។

-ចាត់ចែងរៀបចំដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈ ឱ្យក្រុមហ៊ុនបោះផ្សាយ មូលបត្រ ឬ ចូលរួមដោយផ្ទាល់ ឬមិនផ្ទាល់នៅក្នុងដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈ។

**ខ. ក្រុមហ៊ុនពាណិជ្ជករមូលបត្រ(Securities Dealer)**

អាជីវកម្មពាណិជ្ជករមូលបត្រ គឺជាការជួញដូរមូលបត្រលើគណនីផ្ទាល់ខ្លួន ដោយរ៉ាប់រងហានិភ័យដោយខ្លួនឯង។

**គ. ក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ(Securities Broker)**

អាជីវកម្មឈ្មួញជើងសាមូលបត្រ គឺជាការទិញ ឬលក់មូលបត្រក្នុងនាម និងតាមបញ្ជាអតិថិជនរបស់ខ្លួន ដោយទទួលបាននូវកម្រៃជើងសា។

**ឃ. ក្រុមហ៊ុនផ្តល់ប្រឹក្សាវិនិយោគ(Investment Advisor/Consultant)**

អាជីវកម្មផ្តល់ប្រឹក្សាវិនិយោគ រួមមាន ៖

-ការផ្តល់ប្រឹក្សាអំពីការវិនិយោគលើមូលបត្រ ដល់អ្នកវិនិយោគសាធារណៈ ដោយទទួលបាននូវកម្រៃសេវា។

-ការបោះពុម្ពផ្សាយសេចក្តីវិភាគអំពីការវិនិយោគមូលបត្រ ជូនដល់អ្នកវិនិយោគសាធារណៈ។

**២ លក្ខខណ្ឌតម្រូវ ដើម្បីក្លាយជាក្រុមហ៊ុនមូលបត្រ**

**២.១ ផ្តល់អាជ្ញាបណ្ណដល់ក្រុមហ៊ុនមូលបត្រ**

អាជ្ញាបណ្ណ របស់ក្រុមហ៊ុនមូលបត្រ មានតុល្យភាព ០២(ពីរ)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញអាជ្ញាបណ្ណ។ អាជ្ញាបណ្ណ ដែលសុំបន្តដោយក្រុមហ៊ុនមូលបត្រមានតុល្យភាព០៣(បី)ឆ្នាំគិតចាប់ពីកាលបរិច្ឆេទដែលអាជ្ញាបណ្ណចាស់អស់សុពលភាព។

**២.២ លក្ខខណ្ឌតម្រូវដើមទុន**

-ដើម្បីធ្វើអាជីវកម្មជាក្រុមហ៊ុនធានាទិញមូលបត្រ បុគ្គលដាក់ពាក្យស្នើសុំត្រូវមានមូលធនអប្បបរមាចំនួន៤០.០០០.០០០.០០០(សែសិបពាន់លាន) រៀលដែលក្នុងនោះមូលធនសុទ្ធ ២.០០០.០០០.០០០(ពីរពាន់លាន)រៀល និងត្រូវបានដាក់ប្រាក់តម្កល់ជានាអាជីវកម្ម និងឧបករណ៍តម្កល់ជានាអាជីវកម្មចំនួន ៤.០០០.០០០.០០០(បួនពាន់លាន)រៀល ។

-ដើម្បីធ្វើអាជីវកម្មជាក្រុមហ៊ុនពាណិជ្ជករមូលបត្រ បុគ្គលដាក់ពាក្យស្នើសុំត្រូវមានមូលធនអប្បបរមាចំនួន ២៥.០០០.០០០.០០០(តម្លៃប្រាំពាន់លាន)រៀល ដែលនៅក្នុងនោះមូលធនសុទ្ធអប្បបរមាចំនួន ១.២៥០.០០០.០០០(មួយពាន់ពីររយហាសិបលាន)រៀលនិងត្រូវដាក់ប្រាក់តម្កល់ជានាអាជីវកម្ម និឧបករណ៍តម្កល់ជានាអាជីវកម្មចំនួន ២.៥០០.០០០.០០០(ពីរពាន់ប្រាំរយលាន)រៀល។

-ដើម្បីធ្វើអាជីវកម្មជាក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ បុគ្គលដាក់ពាក្យស្នើសុំត្រូវមានមូលធនអប្បបរមាចំនួន ៦.០០០.០០០.០០០(ប្រាំមួយពាន់លាន)រៀល ដែលនៅក្នុងនោះមូលធនសុទ្ធអប្បបរមាចំនួន ៣០០.០០០.០០០(បីរយលាន)រៀល និងត្រូវដាក់ប្រាក់តម្កល់ជានាអាជីវកម្ម និងឧបករណ៍តម្កល់ជានាអាជីវកម្មចំនួន ១.០០០.០០០.០០០(មួយពាន់លាន)រៀល។

**២.៣ លក្ខខណ្ឌតម្រូវផ្សេងៗ**

ដើម្បីទទួលបានអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណធ្វើអាជីវកម្មជាក្រុមហ៊ុនមូលបត្រ បុគ្គលដាក់ពាក្យស្នើសុំត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

១-ត្រូវបំពេញតាមលក្ខខណ្ឌតម្រូវដែលមានចែងក្នុងមាត្រា ៤០ នៃអនុក្រឹត្យ។

២-ត្រូវបំពេញលក្ខខណ្ឌតម្រូវមូលធន និងត្រូវដាក់នៅធនាគារជាតិនៃកម្ពុជា នូវប្រាក់តម្កល់ជានាអាជីវកម្មនិងឧបករណ៍តម្កល់ជានាអាជីវកម្មដែលកំណត់ដោយ**គ.ម.ក** ទៅតាមប្រភេទអាជីវកម្មមូលបត្រនីមួយៗ។

៣-ត្រូវបំពេញលក្ខខណ្ឌតម្រូវធនធានមនុស្សដូចខាងក្រោម ៖

-ត្រូវមានយ៉ាងហោចណាស់នាយកប្រតិបត្តិ និងអភិបាល ឬសហកម្មសិទ្ធិករម្នាក់ ដែលបានបំពេញលក្ខខណ្ឌតម្រូវដូចមានចែងក្នុងមត្រា ១៨ នៃប្រកាសនេះ។

-ត្រូវមានយ៉ាងហោចណាស់ប្រធានប្រតិបត្តិការ ដែលបានបំពេញលក្ខខណ្ឌតម្រូវដូចមានចែងក្នុងប្រការ ១៩ នៃប្រការនេះ។

-ត្រូវមានប្រធានប្រតិបត្តិការដែលបានបំពេញលក្ខខណ្ឌតម្រូវដូចមានចែងក្នុងប្រការ២០នៃប្រការនេះ។

-ត្រូវមានបុគ្គលិកជំនាញទៅតាមទំហំនៃប្រភេទអាជីវកម្មនីមួយៗ ដូចមានចែងក្នុងប្រការ២១ នៃប្រការនេះ។

-ត្រូវមានបុគ្គលិកជំនាញទៅតាមទំហំនៃប្រភេទអាជីវកម្មនីមួយៗ ដូចមានចែងក្នុងប្រការ២២ នៃប្រការនេះ។

-ត្រូវមានបុគ្គលិកជាន់ខ្ពស់ និងនិយោជិតផ្សេងទៀត។

៤-ត្រូវមានប្រព័ន្ធឧបករណ៍សម្ភារជារូបវន្ត ដូចមានចែងក្នុងប្រការ ២៧ នៃប្រការនេះ។

៥-ត្រូវរៀបចំផែនការអាជីវកម្មសម្រាប់រយៈពេលយ៉ាងតិច០៣(បី)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

៦-ត្រូវបំពេញលក្ខខណ្ឌការគ្រប់គ្រងហានិភ័យ និងការគ្រប់គ្រងផ្ទៃក្នុងដូចខាងក្រោម ៖

-លទ្ធផលនៃការវាយតម្លៃត្រូវមានកម្រិតល្អ ឬល្អណាស់ដូចមានចែងនៅក្នុងឧបសម្ព័ន្ធនៃការប្រកាសនេះ ។

-ពិន្ទុលើការវាយតម្លៃលើធាតុនីមួយៗ ដូចមានក្នុងឧបសម្ព័ន្ធនៃប្រការនេះ

៧-ត្រូវមានផែនការគ្រប់គ្រងហានិភ័យដែលត្រូវបានធ្វើបច្ចុប្បន្នកម្ម និងដែលអាចអនុវត្តបាន ដើម្បីគ្រប់គ្រងហានិភ័យដែលអាចកើតមាន។

៨-មិនធ្លាប់ធ្វើជាភាគហ៊ុនដែលកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោតចំនួនច្រើនលើសលប់ ឬបុគ្គលដែលមានទំនាក់ទំនងពិសេសជាមួយក្រុមហ៊ុនមូលបត្រ ឬគ្រឹះស្ថានហិរញ្ញវត្ថុណាមួយដែលធ្លាប់ត្រូវបានប្រកាសក្ស័យធននៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជាក្នុងរយៈពេល ៥(ប្រាំ)ឆ្នាំ ចុងក្រោយ គិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ លើកលែងតែបុគ្គលដែលត្រូវបានទទួលស្គាល់ដោយសេចក្ដីសម្រេចរបស់តុលាការថា ពុំមានការទទួលខុសត្រូវចំពោះការក្ស័យធននោះ។

៩-មិនធ្លាប់ធ្វើជាភាគហ៊ុនដែលកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោតចំនួនច្រើនលើសលប់ ឬបុគ្គលដែលមានទំនាក់ទំនងពិសេសជាមួយក្រុមហ៊ុនមូលបត្រ ឬគ្រឹះស្ថានហិរញ្ញវត្ថុដែលមានអាជ្ញាបណ្ណរបស់ក្រុមហ៊ុនមូលបត្រ ឬ ស្ថាប័ណ្ណហិរញ្ញវត្ថុនោះត្រូវបានដកហូតនៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល ៥(ប្រាំ)ឆ្នាំចុងក្រោយ គិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ លើកលែងតែបុគ្គលដែលត្រូវបានទទួលស្គាល់ដោយសេចក្ដីសម្រេចរបស់តុលាការថា ពុំមានការទទួលខុសត្រូវចំពោះការដកហូតនេះ។

១០-មិនធ្លាប់ជាបុគ្គលជាប់ពាក់ព័ន្ធនឹងនីតិវិធីដូចជា ការក្ស័យធន ការជំរះបញ្ជីអនុរូបសញ្ញា ឬនីតិវិធីផ្សេងៗទៀតនៅក្នុង ឬ នៅក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល០៥(ប្រាំ)ឆ្នាំចុងក្រោយគិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

**៣.២.៥.ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ**( Agent of Cash Settlement)

បន្ទាប់ពីជួញដូរមូលបត្រ រួចត្រូវធ្វើការទូទាត់សាច់ប្រាក់និងមូលបត្រដែលភាគីអ្នកលក់និងត្រូវផ្ទេរមូលបត្រទៅឱ្យភាគីអ្នកទិញហើយភាគីអ្នកទិញត្រូវផ្ទេរសាច់ប្រាក់ទៅឱ្យអ្នកលក់វិញ។ ការទូទាត់មូលបត្រត្រូវមានការចូលរួមពីក្រុមហ៊ុនមូលបត្រ(តំណាងឱ្យអ្នកលក់និងអ្នកទិញ)និងនាយកដ្ឋានផាត់ទាត់និងទូទាត់មូលបត្រនិងនាយកដ្ឋានរក្សាទុកមូលបត្រ។ ហើយចំណែកឯការទូទាត់សាច់ប្រាក់ត្រូវមានការចូលរួមពីក្រុមហ៊ុនមូលបត្រ(តំណាងឱ្យអ្នកលក់និងអ្នកទិញ)នាយកដ្ឋានផាត់ទាត់និងទូទាត់មូលបត្រនិងភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

**ក. បុគ្គលដែលអាចធ្វើជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ**

បុគ្គលដាក់ពាក្យស្នើសុំនិងត្រូវជាធនាគារពាណិជ្ជដែលទទួលបានអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា ដោយអនុលោមតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងបទប្បញ្ញត្តិពាក់ព័ន្ធរបស់ធនាគារជាតិនិងត្រូវទទួលបានជាមុននូវលិខិតមិនជំទាស់ពីធនាគារជាតិនៃកម្ពុជា។

**ខ. លក្ខខណ្ឌតម្រូវ**

បុគ្គលដាក់ពាក្យស្នើសុំធ្វើជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រត្រូវ៖

១.មានក្របខណ្ឌ និងនីតិវិធីអភិបាលកិច្ចសាជីវកម្មរឹងមាំ។

២.មានភាពរឹងមាំខាងផ្នែកហិរញ្ញវត្ថុ និងសមត្ថភាពប្រតិបត្តិការខ្ពស់។

៣.មានធនធានមនុស្ស ប្រកបដោយចំណេះដឹងសមត្ថភាព និង បទពិសោធន៍ខ្ពស់សមស្រប នៅក្នុងវិស័យមូលបត្រធនាគារហិរញ្ញវត្ថុនិងពាណិជ្ជកម្មសម្រាប់ប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ និងត្រូវបានអត្តចរិកល្អដូចមានចែងក្នុងមាត្រាទី៤០នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន។

៤.មានប្រព័ន្ធបច្ចេកវិទ្យា និងយន្តការនានាដែលធានាឱ្យប្រតិបត្តិការទូទាត់មានល្បឿនរហ័សសុវត្ថិភាព ស្ថេរភាពខ្ពស់។

៥.មានបច្ចេកវិទ្យាដែនធានាការភ្ជាប់លើទំនាក់ទំនងប្រកបដោយប្រសិទ្ធិភាពជាមួយប្រព័ន្ធផាត់ទាត់ និង ទូទាត់មូលបត្រប្រព័ន្ធផាត់ទាត់ និងទូទាត់សាច់ប្រាក់ក្រុមហ៊ុនមូលបត្រដែលជាអតិថិជនរបស់ខ្លួនជាដើម ។

៦.មានប្រព័ន្ធទ្រទ្រង់( Back-up System) និងផែនការយថាភាព(Contingency Plan)សមស្របដើម្បីកាត់បន្ថយនូវហានិភ័យកើតចេញពីអាជីវកម្ម ឬប្រតិបត្តិការណាមួយ( Operational Risks)ជាយថាហេតុ។

៧.មាននីតិវិធីច្បាស់លាស់ ក្នុងការផ្តល់សេវានានាដល់អតិថិជនដែលធ្វើប្រតិបត្តិការជួញដូរមូលបត្រក្នុងការទូទាត់សាច់ប្រាក់។

៨.គោរពតាមលក្ខខណ្ឌតម្រូវពាក់ព័ន្ធនានារបស់ប្រតិបត្តិការប្រព័ន្ធផាត់ទាត់មូលបត្រ។

**គ. កាតព្វកិច្ចរបស់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ**

ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រត្រូវ៖

១.ធ្វើការគ្រប់គ្រងគណនីទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្ររបស់អតិថិជនខ្លួននិងធ្វើការផ្ទេរឬបង្វែរសាច់ប្រាក់រវាងភាគីធ្វើប្រតិបត្តិការជួញដូរមូលបត្រនៅក្នុងទីផ្សារមូលបត្រប្រកបដោយភាពត្រឹមត្រូវនិងតាមកាលកំណត់។

២.ធ្វើប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព។

៣-បំពេញប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រឱ្យដាច់ដោយឡែកពីមុខងារប្រតិបត្តិការធនាគារ( Banking Operations )។

៤.ត្រួតពិនិត្យ និងគ្រប់គ្រងដោយប្រុងប្រយ័ត្នខ្ពស់នូវរាល់ហានិភ័យដែលកើតឡើងពីអាជីវកម្មឬប្រតិបត្តិការណាមួយ។

៥.គោរពយ៉ាងខ្ជាប់ខ្ជួនទៅតាមលក្ខខណ្ឌតម្រូវស្ដីអំពីធនធានមនុស្សធនធានហិរញ្ញវត្ថុនិងបច្ចេកវិទ្យាសម្រាប់ធានាប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រឱ្យដំណើរការប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព។

៦.គោរពតាមវិធាននិងនីតិវិធីពាក់ព័ន្ធនឹងប្រតិបត្តិការប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រនិងវិធានពាក់ព័ន្ធផ្សេងទៀត។

៧.ផ្ដល់ភាពងាយស្រួល ដល់ការប្រើប្រាស់សេវាខ្លួនដើម្បីធានាឱ្យបាននូវសុវត្ថិភាពនិងប្រសិទ្ធភាពនៃប្រតិបត្តិការ។

៨.បំពេញកាតព្វកិច្ចផ្ដល់របាយការណ៍និងព័ត៌មាននានា និងកាតព្វកិច្ចដទៃទៀតឱ្យបានត្រឹមត្រូវដូចមានចែងនៅក្នុងច្បាប់អនុក្រឹត្យប្រកាសនេះនិងបទប្បញ្ញត្តិពាក់ព័ន្ធនានា។

**ឃ. កម្រៃនៃការទទួលស្គាល់ប្រចាំឆ្នាំនិងកម្រៃផ្សេងទៀត**

បុគ្គលដាក់ពាក្យស្នើសុំត្រូវបង់ថ្លៃពាក្យស្នើសុំនិងសោហ៊ុយសិក្សាសំណុំលិខិតចំនួន២.០០០.០០០(ពីរលាន)រៀល។ថ្លៃពាក្យស្នើសុំនិងសោហ៊ុយសិក្សាសំណុំលិខិតនេះមិនត្រូវបានប្រគល់ជូនបុគ្គលដាក់ពាក្យស្នើសុំវិញឡើយទោះបីជាមានបដិសេធលើការទទួលស្គាល់ក៏ដោយ។

បុគ្គលដែលទទួលបានការទទួលស្គាល់ ធ្វើជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រត្រូវបង់ថ្លៃការទទួលស្គាល់ប្រចាំឆ្នាំចំនួន៤០.០០០.០០០(សែសិបលាន)រៀលដោយគិតចាប់ពីការបរិច្ឆេទនៃការទទួលស្គាល់។សម្រាប់ឆ្នាំបន្តបន្ទាប់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រត្រូវបង់ថ្លៃការទទួលស្គាល់ប្រចាំឆ្នាំយ៉ាងយូរ៣០(សាមសិប)ថ្ងៃមុនថ្ងៃខែដែលទទួលបានការទទួលស្គាល់។

**ង. បញ្ជីឈ្មោះភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ**

| នាមករណ៍ក្រុមហ៊ុន | | អាសយដ្ឋាន និងលេខទំនាក់ទំនង |
|---|---|---|
| ធនាគារ អេស៊ីលីដា<br>ធនាគារ អេស៊ីលីដា ភីអិលស៊ី ភីអិលស៊ី<br>ACLEDA Bank Plc. | អាស័យដ្ឋាន | : អគារលេខ ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>: ០២៣ ៩៩៨ ៤៤៤<br>: ០២៣ ៩៩៨ ៦៦៦ |
| ធនាគារ កាណាឌីយ៉ា ក.អ<br>CANADIA Bank Plc | អាស័យដ្ឋាន | : វិមានកាណាឌីយ៉ា អគារលេខ៣១៥ ផ្លូវព្រះអង្គឌួង (កែងមហាវិថីព្រះមុនីវង្ស) សង្កាត់វត្តភ្នំ ខណ្ឌដូនពេញរាជធានីភ្នំពេញ<br>: ០២៣ ៨៦៨ ២២២<br>: ០២៣ ២១៥ ០៨៥ |
| ធនាគារ វិនិយោគនិងអភិវឌ្ឍកម្ពុជា ភីអិលស៊ី<br>Bank for Investment and Development of Cambodia Plc. | អាស័យដ្ឋាន | : អគារលេខ៣៧០ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ<br>:០២៣៦៧១៦៨៧០<br>: ០២៣ ២២០ ៥១១ |

**៣.២.៦ អ្នកចូលរួមផ្សេងៗទៀត ក្នុងទីផ្សារមូលបត្រ**(Other Market Participants)

ភ្នាក់ងារក្រុមហ៊ុនបោះផ្សាយ រួមមាន៣ ៖

១. ភ្នាក់ងារបញ្ជិកាមូលបត្រ(Securities Registrar Agent)

២. ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ(Securities Transfer Agent)

៣. ភ្នាក់ងារទូទាត់ជំនួស(Paying Agent or Settlement Agent)

**ក. តួនាទី និងភារកិច្ចរបស់ភ្នាក់ងារក្រុមហ៊ុនបោះផ្សាយ**

**១.ភ្នាក់ងារបញ្ជិកាមូលបត្រ**(Securities Registrar Agent) សំដៅដល់បុគ្គលដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក** ឱ្យផ្ដល់សេវាក្នុងនាមក្រុមហ៊ុនបោះផ្សាយ ក្នុងក្របខណ្ឌនៃការបោះផ្សាយលក់មូលបត្រដូចខាងក្រោម ៖

-គ្រប់គ្រងឱ្យបានត្រឹមត្រូវនូវដំណើរការនៃការធ្វើបរិវិសកម្មនិងការបែងចែកមូលបត្រស្របតាមនីតិវិធីដោះស្រាយលក់មូលបត្រ។

-កត់ត្រាបញ្ជីកម្មសិទ្ធិករមូលបត្រក្រោយពេលធ្វើការបែងចែកមូលបត្រត្រូវបានបញ្ចប់នៅទីផ្សារដំបូង។

-ធ្វើរបាយការណ៍ស្ដីពីការបញ្ចប់ និងជោគជ័យនៃការរក្សាទុកមូលបត្រនៅក្នុងប្រតិបត្តិកររក្សាទុកមូលបត្រជូនក្រុមហ៊ុនបោះផ្សាយ និង **គ.ម.ក** ។

-ជូនដំណឹងដល់កម្មសិទ្ធិករមូលបត្រ ដោយបញ្ជាក់ពីភាពជាម្ចាស់លើមូលបត្រដែលបានធ្វើបរិវិសកម្មមូលបត្ររបស់ក្រុមហ៊ុនបោះផ្សាយ។

-សេវាពាក់ព័ន្ធដទៃទៀតដែលទទួលបានការអនុញ្ញាតពី **គ.ម.ក** ។

**២.ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ** (Securities Transfer Agent) សំដៅដល់បុគ្គលដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក** ឱ្យផ្ដល់សេវាក្នុងនាមក្រុមហ៊ុនបោះផ្សាយក្រោយពេលមូលបត្រត្រូវបានបែងចែកទៅឱ្យអ្នកធ្វើបរិវិសកម្មដូចខាងក្រោម៖

-រក្សា និងគ្រប់គ្រងបញ្ជីកម្មសិទ្ធិករមូលបត្ររួមទាំងព័ត៌មានលម្អិតរបស់កម្មសិទ្ធិករមូលបត្រឱ្យមានសង្គតភាពជាមួយនឹងកំណត់ត្រារបស់ប្រតិបត្តិកររក្សាទុកមូលបត្រ។

-រដ្ឋបាលកិច្ចពាក់ព័ន្ធនឹងការផ្លាស់ប្ដូរកម្មសិទ្ធិករធ្វើរបាយការណ៍ស្ថិតិ និងព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងសកម្មភាពរបស់ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ។

-រៀបចំការងារពាក់ព័ន្ធនឹងកម្មសិទ្ធិករមូលបត្រ ដែលត្រូវផ្ដល់ដោយក្រុមហ៊ុនបោះផ្សាយដូចជាការជូនដំណឹងអំពីការបែងចែកភាគលាភ និងការបង់ការប្រាក់ជាដើម។

-បញ្ជូនរបាយការណ៍ និងព័ត៌មានផ្សេងៗរបស់ក្រុមហ៊ុនបោះផ្សាយទៅដល់កម្មសិទ្ធិករមូលបត្រ និងដោះស្រាយបញ្ហាទាក់ទងនឹងភាពជាម្ចាស់លើមូលបត្រពាក់ព័ន្ធនឹងសេវារបស់ភ្នាក់ងារចុះផ្ទេរមូលបត្រ។

-សេវាពាក់ព័ន្ធដទៃទៀតដែលទទួលបានការអនុញ្ញាតពី **គ.ម.ក** ។

**៣.ភ្នាក់ងារទូទាត់ ឬភ្នាក់ងារទូទាត់ជំនួស**(Paying Agent or Settlement Agent) សំដៅដល់បុគ្គលដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក** ឱ្យផ្ដល់សេវាក្នុងនាមក្រុមហ៊ុនបោះផ្សាយដូចខាងក្រោម ៖

-គណនាភាគលាភ ការប្រាក់ ប្រាក់ដើម ឬការទូទាត់ផ្សេងទៀត ដែលត្រូវផ្ដល់ឱ្យដល់កម្មសិទ្ធិករមូលបត្រ ឬភាគីពាក់ព័ន្ធតាមការណែនាំរបស់ក្រុមហ៊ុនបោះផ្សាយ។

-ធ្វើការទូទាត់ជូនកម្មសិទ្ធិករមូលបត្រ ឬភាគីពាក់ព័ន្ធក្នុងនាមក្រុមហ៊ុនបោះផ្សាយ។

-បញ្ជូនព័ត៌មានចាំបាច់ដែលពាក់ព័ន្ធនឹងការទូទាត់ ឬព័ត៌មានផ្សេងទៀតដល់កម្មសិទ្ធិករមូលបត្រ និងរៀបចំរបាយការណ៍ពាក់ព័ន្ធនឹងការទូទាត់ទាំងនេះ ជូនទៅក្រុមហ៊ុនបោះផ្សាយ និង **គ.ម.ក** តាមការចាំបាច់។

ឃ-សេវាពាក់ព័ន្ធដទៃទៀតដែលទទួលបានការអនុញ្ញាតពី **គ.ម.ក** ។

### ខ. លក្ខខណ្ឌនៃការទទួលស្គាល់

### ១. ការដាក់ពាក្យស្នើសុំ

បុគ្គលដែលមានបំណងធ្វើជាភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ឬភ្នាក់ងារទូទាត់ជំនួស គឺជាក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្មស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងត្រូវដាក់ពាក្យស្នើសុំដើម្បីបានការទទួលស្គាល់ពីអគ្គនាយកនៃ **គ.ម.ក** ។

### ២. បុគ្គលដាក់ពាក្យស្នើសុំ

បុគ្គលដាក់ពាក្យស្នើសុំធ្វើជា ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ឬភ្នាក់ងារទូទាត់អាចជា៖

-ប្រតិបត្តិកររក្សាទុកមូលបត្រ ដែលទទួលបានការអនុញ្ញាតពី **គ.ម.ក** ។

-ធនាគារពាណិជ្ជដែលទទួលបានអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា។

-ក្រុមហ៊ុនមូលធនផ្សេងទៀត ដូចមានចែងក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។

ក្នុងករណីបុគ្គលដាក់ពាក្យស្នើសុំធ្វើជាភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ដែលមិនមែនជាប្រតិបត្តិកររក្សាទុកមូលបត្រ បុគ្គលត្រូវមានកិច្ចសន្យាជាមួយប្រតិបត្តិកររក្សាទុកមូលបត្រស្តីពីការផ្តល់ព័ត៌មាននៃការផ្លាស់ប្តូរកំណត់ត្រាភាពជាម្ចាស់កម្មសិទ្ធិលើមូលបត្រ ដែលគ្រប់គ្រងដោយប្រតិបត្តិកររក្សាទុកមូលបត្រ។

### ៣. លក្ខខណ្ឌតម្រូវសម្រាប់បុគ្គលដាក់ពាក្យស្នើសុំ

បុគ្គលដាក់ពាក្យស្នើសុំធ្វើជា ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ឬភ្នាក់ងារទូទាត់ជំនួសត្រូវ ៖

-មានដើមទុនអប្បបរមាជារូបិយវត្ថុជាតិចំនួន ៖

.២០០.០០០.០០០(ពីររយលាន)រៀល ក្នុងករណីស្នើសុំធ្វើជាភ្នាក់ងារបញ្ជិកាមូលបត្រ។

.២០០.០០០.០០០(ពីររយលាន)រៀល ក្នុងករណីស្នើសុំធ្វើជាភ្នាក់ងារចុះញ្ជីផ្ទេរមូលបត្រ។

.៥០០.០០០.០០០(ប្រាំរយលាន)រៀល ក្នុងករណីស្នើសុំធ្វើជាភ្នាក់ងារទូទាត់ជំនួស។

-ដាក់ប្រាក់តម្កល់ ១០(ដប់)ភាគរយ នៃដើមទុនអប្បបរមានៅក្នុងគណនីរបស់ **គ.ម.ក** នៅធនាគារជាតិនៃកម្ពុជា។ ក្នុងករណីចាំបាច់ប្រាក់តម្កល់នេះ អាចដកយកមកប្រើប្រាស់បានដោយមានការអនុញ្ញាតជាមុនសិនពី **គ.ម.ក**។

-មានវិធានស្តីពីសេវា និងយន្តការក្នុងការផ្តល់សេវា មានប្រព័ន្ធបច្ចេកវិទ្យា សម្រាប់ធ្វើប្រតិបត្តិការ និងប្រព័ន្ធទ្រទ្រង់ដើម្បីធានាឱ្យបាននូវប្រតិបត្តិការប្រកបដោយសុវត្ថិភាព ប្រសិទ្ធិភាព និងចិរភាព។

-មានអង្គភាព ឬផ្នែកដាច់ដោយឡែកដែលមានទ្រព្យ និងធនធានមនុស្សគ្រប់គ្រាន់ និងត្រូវបានគ្រប់គ្រងត្រឹមត្រូវ សម្រាប់ផ្តល់សេវាជាភ្នាក់ងារបញ្ជិកាមូលបត្រ ឬភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ឬភ្នាក់ងារទូទាត់ដើម្បីធានាបាននូវប្រសិទ្ធិភាព គណនេយ្យភាព តម្លាភាព និងភាពទទួលខុសត្រូវ។ ករណីបុគ្គលដាក់

ពាក្យស្នើសុំធ្វើជាភ្នាក់ងារបញ្ជិកាមូលបត្រភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់បុគ្គលនេះអាចមានរចនាសម្ពន្ធមួយ សម្រាប់បំពេញសេវាភ្នាក់ងារទាំងបីនេះនៅក្នុងអង្គភាព ឬផ្នែកមួយដាច់ដោយឡែក។

-មានបុគ្គលដែលត្រូវតែងតាំងជាប្រធានផ្នែកប្រតិបត្តិការក្នុងការផ្តល់សេវាជាភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ឬភ្នាក់ងារទូទាត់ជនួស ដែលបំពេញលក្ខខណ្ឌតម្រូវ។ ធនាគារពាណិជ្ជ ឬប្រតិបត្តិកររក្សាទុកមូលបត្រអាចបង្កើតបុត្រសម្ព័ន្ធដើម្បីដាក់ពាក្យស្នើសុំធ្វើភ្នាក់ ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ឬភ្នាក់ងារទូទាត់ជំនួស។ ក្នុងករណីបុគ្គលដាក់ពាក្យស្នើសុំជាធនាគារពាណិជ្ជ ឬប្រតិបត្តិកររក្សាទុកមូលបត្រ លក្ខខណ្ឌតម្រូវស្តីពីដើមទុនអប្បបរមា។ក្នុងករណីបុគ្គលដាក់ពាក្យស្នើសុំ ជាក្រុមហ៊ុនមូលធនផ្សេងទៀត ដែលកំពុងធ្វើសកម្មភាពធុរកិច្ច បុគ្គលដាក់ពាក្យស្នើសុំត្រូវបន្ថែមដើមទុន លើដើមទុនបច្ចុប្បន្ន។

## ៤. លក្ខណៈសម្បត្តិរបស់បុគ្គលដាក់ពាក្យស្នើសុំ

បុគ្គលដាក់ពាក្យស្នើសុំ បុគ្គលដែលត្រូវតែងតាំងជាអភិបាល និងបុគ្គលិកជាន់ខ្ពស់របស់បុគ្គលដាក់ពាក្យស្នើសុំ ត្រូវគោរពលក្ខខណ្ឌតម្រូវដូចខាងក្រោម ៖

-មានលក្ខណសម្បត្តិនិងអត្តចរិត។

-មិនធ្លាប់ត្រូវបានប្រកាសក្ស័យធន ឬមិនធ្លាប់បង្កឱ្យក្រុមហ៊ុនមួយ ឬច្រើនឈានទៅរកភាពក្ស័យធនក្នុងរយៈពេល ០៥(ប្រាំ)ឆ្នាំចុងក្រោយគិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំ។

-មិនធ្លាប់ប្រព្រឹត្តិអំពើអ្វី ដែលនាំឱ្យប៉ះពាល់ដល់ដំណើរការទីផ្សារមូលបត្រ ឬនៅក្នុងវិស័យហិរញ្ញវត្ថុ។

-មិនធ្លាប់ប្រព្រឹត្តិអ្វី ដែលប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈ។

## ៥.ឯកសារភ្ជាប់ជាមួយពាក្យស្នើសុំ

បុគ្គលដាក់ពាក្យស្នើសុំត្រូវបំពេញបែបបទនៃពាក្យស្នើសុំទៅតាមទម្រង់ដែលបានកំណត់ដោយ **គ.ម.ក** ដោយភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

-វិញ្ញាប័នបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ថតចម្លងមានបញ្ជាក់ត្រឹមត្រូវ។

-ប័ណ្ណប៉ាតង់ ឬវិញ្ញាប័នបត្រចុះបញ្ជីអាករលើតម្លៃបន្ថែមថតចម្លងមានបញ្ជាក់ត្រឹមត្រូវ ។

-លក្ខន្តិកៈក្រុមហ៊ុន ថតចម្លងមានបញ្ជាក់ត្រឹមត្រូវ។

-លិខិតបញ្ជាក់ពីដើមទុនអប្បបរមាដូចមានចែងក្នុងប្រការ៥ នៃប្រកាសនេះ។

-រចនាសម្ព័ន្ធគ្រប់គ្រងមុខងារ និងការទទួលខុសត្រូវរបស់បុគ្គលិកនីមួយៗក្នុងរចនាសម្ព័ន្ធគ្រប់គ្រង។

-វិធានស្តីពីសេវាផែនការអាជីវកម្មសម្រាប់រយៈពេលយ៉ាងតិច០៣(បី)ឆ្នាំ ដោយគិតចាប់ពីកាលបរិច្ឆេទនៃការដាពាក្យស្នើសុំ។

-ផែនការគ្រប់គ្រងហានិភ័យ។

-បញ្ជីរាយនាមក្រុមហ៊ុនបោះផ្សាយ ដែលបុគ្គលដាក់ពាក្យស្នើសុំធ្លាប់ផ្តល់ ឬមានបំណងផ្តល់សេវាភ្នាក់ងារបញ្ជិកាមូលបត្រ ឬសេវាកម្មភ្នាក់ងារផ្ទេរមូលបត្រ ឬសេវាភ្នាក់ងារទូទាត់។

## គ. ការទទួលស្គាល់កម្រៃ និងបន្ទុក

### ១.កម្រៃនៃការទទួលស្គាល់ប្រចាំឆ្នាំ និងកម្រៃផ្សេងទៀត

បុគ្គលដាក់ពាក្យស្នើសុំ ត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិតចំនួន១,០០០,០០០ (មួយលាន)រៀន នៅពេលដាក់ពាក្យស្នើសុំធ្វើជាភ្នាក់ងារនីមួយៗ។ ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិតនេះ មិនត្រូវបានប្រគល់ជូនបុគ្គលដាក់ពាក្យស្នើសុំវិញឡើយ ទោះបីជាមានការបដិសេធលើពាក្យស្នើសុំក៏ដោយ។

បុគ្គលដែលទទួលបានការទួលទស្គាល់ ត្រូវបង់ថ្លៃការទទួលស្គាល់ប្រចាំឆ្នាំដូចខាងក្រោម ៖

-ភ្នាក់ងារបញ្ជិកាមូលបត្រត្រូវបង់ចំនួន ១.០០០.០០០(មួយលាន)រៀល។

-ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រត្រូវបង់ចំនួន ១.០០០.០០០(មួយលាន)រៀល។

-ភ្នាក់ងារទូទាត់ជំនួសត្រូវបង់ចំនួន ២.០០០.០០០(ពីរលាន)រៀល។

សម្រាប់ឆ្នាំបន្តបន្ទាប់ភ្នាក់ងារនីមួយៗ ត្រូវបង់ថ្លៃការទទួលស្គាល់ប្រចាំឆ្នាំយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ មុនថ្ងៃខែដែលទទួលបានការទទួលស្គាល់។

**២. ការត្រួតពិនិត្យដោយ គ.ម.ក**

ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ឬភ្នាក់ងារទូទាត់ជំនួសអាចត្រូវបានត្រួតពិនិត្យដែលធ្វើឡើងដោយ **គ.ម.ក** លើស្ថានភាព និងប្រសិទ្ធិភាពនៃប្រតិបត្តិការសេវាកម្មរបស់ភ្នាក់ងារនីមួយៗ។

ភ្នាក់ងារនីមួយៗត្រូវផ្តល់កិច្ចសន្យាសហការល្អដល់មន្ត្រីត្រួតពិនិត្យរបស់ **គ.ម.ក** ក្នុងគោលដៅធានានូវប្រសិទ្ធិភាពការងារ។

បន្ទាប់ពីទទួលបានការទទួលស្គាល់ ភ្នាក់ងារបញ្ជិកាមូលបត្រភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ឬភ្នាក់ងារទូទាត់ជំនួសត្រូវគោរពតាមលក្ខខណ្ឌ។

**៣.វិធានការពិន័យអន្តរកាណ៍**

ដោយមិនទាន់គិតពីទោសទណ្ឌផ្សេងទៀតដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិក្នុងវិស័យមូលបត្រ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ភ្នាក់ងារនីមួយៗ ដែលប្រព្រឹត្តល្មើសនឹងប្រកាសនេះ ត្រូវទទួលការផាកពិន័យអន្តរការណ៍ពី**គ.ម.ក**ជាប្រាក់ពី៥.០០០.០០០(ប្រាំលាន)រៀលដល់ ២០.០០០.០០០ (ម្ភៃលាន)រៀល។ ដោយឡែកចំពោះការយឺតយ៉ាងក្នុងការបង់កម្រៃនៃការទទួលស្គាល់ភ្នាក់ងារបញ្ជិកាមូបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រឬភ្នាក់ងារទូទាត់ជំនួសត្រូវទទួលការផាកពិន័យអន្តរការណ៍ជាប្រាក់ ១០០.០០០(ដប់ម៉ឺន)រៀល ក្នុង ១(មួយ)ថ្ងៃ ។

## ឃ. បញ្ជីឈ្មោះភ្នាក់ងារក្រុមហ៊ុនបោះផ្សាយ ឬអ្នកចូលរួម ផ.ម.ក
## (ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ជំនួស)

| នាមករណ៍ក្រុមហ៊ុន | | អាសយដ្ឋាន និងលេខទំនាក់ទំនង |
|---|---|---|
| | ធនាគារ អេស៊ីលីដា ភីអិលស៊ី<br>Acleda Bank Plc. | អាគារលេខ ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>ទូរសព្ទ : ០២៣ ៩៩៨ ៧៧៧<br>ទូរសារ : ០២៣ ៩៩៨ ៦៦៦<br>អ៊ីម៉ែល : acledabank@acledabank.com.kh<br>គេហទំព័រ : www.acledabank.com.kh |
| | ក្រុមហ៊ុន ត្រាយខ័រ ស៊ីឃ្យួរីធី សឺវីស ភីអិលស៊ី<br>Tricor Securities Services PLC. | អាគារលេខ អាអា០៦ ផ្លូវ ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ<br>ទូរសព្ទ : ០២៣ ៩៨៧ ១០០<br>ទូរសារ : ០២៣ ៩៨៧ ៣៨៨<br>អ៊ីម៉ែល : info@tricorcambodia.com<br>គេហទំព័រ : www.tricorcambodia.com |
| | ធនាគារ វីង (ខេមបូឌា) ម.ក<br>Wing Bank (Cambodia) Plc. | វីងថៅវើ មហាវិថីព្រះមុនីវង្ស (ផ្លូវលេខ ៩៣) កែងមហាវិថីកម្ពុជាក្រោម (ផ្លូវលេខ ១២៨) ភូមិ ៦ សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។<br>ទូរសព្ទ : (៨៥៥) ២៣ ៩៩៩ ៩៨៩<br>អ៊ីម៉ែល : care.centre@wingbank.com.kh<br>គេហទំព័រ : www.wingbank.com.kh |
| | ធនាគារ កាណាឌីយ៉ា ក.អ<br>Canadia Bank Plc. | អាគារលេខ ៣១៥ មហាវិថីព្រះមុនីវង្សកែងផ្លូវព្រះ អង្គឌួង សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។<br>ទូរសព្ទ : ០២៣ ៨៦៨ ២២២<br>អ៊ីម៉ែល : canadia@canadiabank.com.kh |

**៣.២.៧.វិនិយោគិន**(Investors)

**លក្ខណៈទូទៅនៃវិនិយោគិន(សញ្ជាតិខ្មែរ ឬបរទេស)**

វិនិយោគិនសាធារណៈទោះបីមានសញ្ជាតិខ្មែរ ឬបរទេសក្តីសុទ្ធសឹងតែមានសិទ្ធិស្មើគ្នា ក្នុងការទិញ ឬលក់មូលបត្រដោយគ្មានការរិតត្បិតពីច្បាប់នោះឡើយ លើកលែងតែការជួញដូរមូលបត្រដែលធ្វើឡើងនៅទីផ្សារដំបូង ដែលប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ បានបម្រុងទុកភាគហ៊ុនសម្រាប់លក់ឲវិនិយោគិន សញ្ជាតិខ្មែរយ៉ាងតិច ២០% នៃសំណើលក់ជាសរុប។ ចំនែក ៨០% ដែលនៅសល់បើកចំហចំពោះវិនិយោគិនសញ្ជាតិខ្មែរនិងវិនិយោគិនបរទេស។

**ក. សមាសភាពអ្នកវិនិយោគ**

វិនិយោគិន គឺជាអ្នកទិញមូលបត្រទោះជារយៈពេលខ្លីក្តី ឬវែងក្តី។ វិនិយោគិនអាចជារូបវ័ន្តបុគ្គល ឬជានិតិបុគ្គល ដូចជា ក្រុមហ៊ុន អង្គការ សាសនា ក្លឹប សមាគ។ល។ ក្រុមហ៊ុនបោះផ្សាយដែលជាអ្នកបោះលក់មូលបត្រ ពេលខ្លះក៏ទិញមូលបត្រគេចូលមកវិញដែរ ក្នុងគោលបំណងធ្វើហិរញ្ញប្បទានបន្ថែម។

**ខ. ប្រភេទអ្នកវិនិយោគ**

**១. អ្នកវិនិយោគរយៈពេលខ្លី(Short Term Investment/Trading)**

អ្នកវិនិយោគរយៈពេលខ្លី គឺសំដៅដល់អ្នកវិនិយោគរយៈពេលក្រោម៣ខែ(speculators)។ ក្រុមអ្នកវិនិយោគនេះទិញហើយលក់ភ្លាមៗទោះជាខាតក្តី ឬចំណេញក្តី។ ទីផ្សារមានសកម្មភាពភាព ទីផ្សាររញ្ជួយ ទីផ្សារចលាចល ទីផ្សារភ្លឹបភ្លែត,ដោយសារពួកនេះ។ បើគ្មានពួកនេះទេ ក៏គ្មានលក្ខណៈទាំងអស់នេះដែរ។ ដើម្បីទប់ទល់នូវទីផ្សារចលាចល រដ្ឋនានាក្នុងលោកបានចែងច្បាប់ចងក្នុងទីផ្សារហ៊ុន ដូចជា អ្នក វិនិយោគទាំងអស់ ត្រូវតែបើកគណនីនៅក្នុងក្រុមហ៊ុនមូលបត្រណាមួយក៏បាន ដែលទទួលស្គាល់ដោយ SECC ហើយការផ្ទេរប្រាក់ត្រូវតែឆ្លងកាត់តាមរយៈនេះ។

**២. អ្នកវិនិយោគរក្សាទុកសម្រាប់លក់ចេញ(Available for Sale Investment)**

អ្នកវិនិយោគរក្សាទុកសម្រាប់លក់ចេញ គឺសំដៅដល់អ្នកវិនិយោគរយៈពេលចន្លោះពី ៣ខែ ដល់ក្រោម១ឆ្នាំ។ កាលណាទិញហើយគេមិនលក់ចេញភ្លាមនោះទេ។ គេទុកនៅក្នុងដៃគេមួយរយៈកាល។ ឱកាសមាសមកដល់(ទីផ្សារល្អ)គេនឹងលក់ចេញភ្លាម។ ដូចជាមូលបត្ររដ្ឋាករទឹក ឥចឹងតម្លៃហ៊ុនធ្លាក់ថ្លៃរហូតដល់ពេលណាមួយដែលគេវិភាគមើលថា(មើលប្រវត្តិរបស់វាតាមរយៈឯកសារនៃការបង្ហាញព័ត៌មានលម្អិតក្នុងរបាយការណ៍ហ/វ) តម្លៃវាប្រហែលជាលែងធ្លាក់ហើយ(គ្មាននរណាដឹងមុនទេ ទោះជាសិក្សាហិរញ្ញវត្ថុដល់កម្រិតណាក៏ដោយ ប៉ុន្តែនៅគ្រាន់បើជាងមិនសិក្សា) គេទិញវាភ្លាម។ គាប់ជួនទិញហើយវាធ្លាក់ថ្លៃបន្ថែមទៀតក៏គេមិនសូវភ័យដែរ។ ដល់ពេលមួយវាឡើងថ្លៃវិញ គេមិនកញ្ជ្រោលចិត្តទេ គេនៅសំងំស្ងៀម។ គេចាំមើលទីផ្សារវាឡើងដល់កម្រិតអតិបរិមា (គ្មាននរណាដឹងមុននោះទេ)គេនឹងលក់វាចេញភ្លាម។ អ្នកវិនិយោគបែបនេះ ត្រូវមានអារម្មណ៍មូលនៅលើទីផ្សារហ៊ុន ចាំឃ្លាំមើលទាំងបរិមាណ និងទឹកប្រាក់របស់អតិថិជនជួញដូរក្នុង១ថ្ងៃៗ។

-ការវិភាគអនុបាត(Ratio)នៅតែវិភាគដូចអ្នកវិនិយោគរយៈពេលវែងដែរ។

-អ្នកវិនិយោគបែបនេះ មិនសូវជាធ្វើឱ្យទីផ្សារហ៊ុនចលាចលនោះទេ។

-ការវិនិយោគរបៀបនេះមិនខុសពីអ្នកវិនិយោគទៅលើដីដែរកាលណាគេទិញដី ហើយដីនោះដែរគេ

មិនមានគម្រោងទុកទេ គេនឹងលក់ចេញនៅពេលណាចំណេញបានល្មម ដើម្បីយកប្រាក់នេះទៅ វិនិយោគដីផ្សេងទៀត បើគេមើលឃើញថា ដីទីកន្លែងផ្សេងនោះបានចំណេញជាង។

-គុណវិបត្តរបស់វា នៅពេលក្រុមហ៊ុនមានផលល្អអាក្រក់ក្ស័យធន គឺអ្នកនោះនឹងទទួលឥទ្ធិពលឬអាចរលាយដូចគ្នា។ ប៉ុន្តែការទទួលផលហានិភ័យបែបនេះមានកម្រិតតិចជាងការទិញរយៈពេលយូរ។

-កាសីណូណាហ្គាគ្មានការវិនិយោគរបៀបនេះឡើយ។

-ក្នុងការធ្វើរបាយការណ៍គណនេយ្យពួក Short Term Investment ដូច្នេះគេ Classifiedវាជា Current Assets និងដាក់ឈ្មោះហៅថាAvailable-For-Sale និងMeasureវាជា Fair Value។ តម្លៃវាឡើងចុះ នៅគ្រប់ចុងការិយបរិច្ឆេទ (Reporting Period) ត្រូវRecognized វាជា Equities។

-មានបង្រៀននៅក្នុង Intermediate Accountingក្នុងឆ្នាំទី៣។

### ៣. អ្នកវិនិយោគរយៈពេលវែង(Long Term Investment)

អ្នកវិនិយោគរយៈពេលវែង គឺសំដៅដល់អ្នកវិនិយោគរយៈពេលលើសពីមួយឆ្នាំឡើងទៅ។ កាលណាទិញមូលបត្រ ហើយគេមិនងាយលក់ចេញវិញទេ។ គេទិញក្នុងគោលបំណងយកភាគលា (Dividend) និងសង្ឃឹមថា គេនឹងទទួលបានតម្លៃហ៊ុនកាន់តែឡើងថ្លៃនាពេលអនាគតបន្តបន្ទាប់ដោយសារភាគទុនក្នុងសន្លឹកកាន់តែធំទៅៗ(Book Value Per Share)។ ភាគទុនក្នុង១សន្លឹកកាន់តែធំទៅៗ ក៏ដោយសារតែអ្នកបោះលក់(Issuer) ពេលមានចំណេញមិនដែលយកប្រាក់ចំណេញទៅចែកទាំងអស់នោះទេ គឺយកតែប្រមាណ ពី ៤០%-៦០% ប៉ុណ្ណោះបែងចែកឱ្យម្ចាស់ភាគហ៊ុន និងមួយចំនួនសម្រាប់ធ្វើអ្វីផ្សេងទៀត នៅសល់ប៉ុន្មានគឺគេតម្កល់ទុកនៅក្នុងទុន ។ល។ អ្នកវិនិយោគរយៈពេលវែងរបៀបនេះ ត្រូវឃ្លាំមើល ជាប្រចាំនូវអនុបាត (Ratio) សំខាន់ៗមួយចំនួន: Dividend Per Share, EPS(Basic & Dilutive), BV Per Share, P/E... រួមទាំងនយោបាយ សេដ្ឋកិច្ច សន្តិសុខសង្គម (ក្នុងប្រទេស តំបន់ ពិភពលោក)។ល។

-ការវិនិយោគរបៀបនេះ មិនខុសពីអ្នកវិនិយោគទៅលើដីដែរ។ កាលណាគេទិញដី ដីណាបានល្អគេទុកដីនោះធ្វើជាកេរ្តិ៍ដល់កូនដល់ចៅរបស់គេ។ ទោះជាយ៉ាងណាក៏ដោយគេធ្វើ ដូច្នេះបានលុះត្រាតែមាននៅសល់សាច់ប្រាក់ទំនេររបស់គេច្រើនប្រើមិនអស់។

-គុណវិបត្តិរបស់វា នៅពេលក្រុមហ៊ុនមានផលល្អ អាក្រក់ ក្ស័យធន គឺអ្នកនោះនឹងទទួលឥទ្ធិពលឬអាចរលាយដូចគ្នា។

-កាសីណូណាហ្គាគ្មានការវិនិយោគរបៀបនេះឡើយ។

-ក្នុងការធ្វើរបាយការណ៍គណនេយ្យពួកLong Term Investment ដូច្នេះគេClassified វាជា Non-Current Assets ហើយ Measure វាជា Fair Value។ តម្លៃវាឡើងចុះ នៅគ្រប់ចុងការិយបរិច្ឆេទ (Reporting Period) ត្រូវRecognized វាជា Equities។

### ៤. ការលើកទឹកចិត្តស្តីពីពន្ធដារក្នុងវិស័យមូលបត្រកម្ពុជា

អនុក្រឹត្យលេខ៧០ អនក្រ បក ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១ ស្តីពីការលើកចិត្តពន្ធដារក្នុងវិស័យមូលបត្រ។

#### ក. វិសាលភាព

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តក្នុងព្រះរាជាណាចក្រកម្ពុជាចំពោះ៖

១-ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ(Equity Securities) និងមូលបត្របំណុល(Liability Securities)ជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពីគណៈកម្មការមូលបត្រកម្ពុជា(គ.ម.ក) និងបានចុះបញ្ជី (Listed)ជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត(Registered Securities Exchange)។

២-អ្នកវិនិយោគសាធារណៈដែលកាន់កាប់ និងទិញ-លក់មូលបត្រកម្មសិទ្ធិ និងមូលបត្របំណុល ដែលបានបោះផ្សាយលក់ជាសាធារណៈ និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត។ សម្រាប់គោលដៅនៃអនុក្រឹត្យនេះ អ្នកវិនិយោគសាធារណៈរួមបញ្ចូលទាំងអ្នកវិនិយោគនិវាសនជន និងអនិវាសនជន។

**ខ. ចំពោះក្រុមហ៊ុនបោះផ្សាយ**

ការលើកទឹកចិត្តពន្ធដារទៅលើពន្ធប្រាក់ចំណូល(Profit Tax) ចំពោះក្រុមហ៊ុនបោះផ្សាយលក់ មូលបត្រកម្មសិទ្ធិ និងមូលបត្របំណុលជាសាធារណៈ។

ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និងមូលបត្របំណុលជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពី គ.ម.ក និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត ត្រូវបំពេញបែបបទជូន អគ្គនាយកដ្ឋានពន្ធដារតាមរយៈគ.ម.ក ដើម្បីទទួលបាននូវការលើកទឹកចិត្ត ដោយបន្ថយពន្ធលើប្រាក់ចំណូល ចំនួន៥០(ភាគរយ)នៃពន្ធលើប្រាក់ចំណូល(Profit Tax)ក្នុងរយៈពេល៣(បី)ឆ្នាំ។ រយៈពេលនៃការលើកទឹកចិត្ត៣(បី)ឆ្នាំខាងលើនេះត្រូវគិតចាប់ផ្តើមពី៖

១.ដើមឆ្នាំជាប់ពន្ធដែលមូលបត្រនោះ ត្រូវបានបោះផ្សាយលក់ជាសាធារណៈក្នុងករណីដែលការបោះផ្សាយលក់នោះធ្វើឡើងក្នុងអំឡុងពេល៦(ប្រាំមួយ)ខែដើមឆ្នាំជាប់ពន្ធនោះ។

២.ដើមឆ្នាំជាប់ពន្ធបន្ទាប់ពីឆ្នាំជាប់ពន្ធដែលមូលបត្រនោះត្រូវបានបោះផ្សាយលក់ជា សាធារណៈក្នុងករណីដែលការបោះផ្សាយលក់នោះ ធ្វើឡើងក្នុងអំឡុងពេល៦(ប្រាំមួយ) ខែចុងឆ្នាំជាប់ពន្ធ។

**គ. ចំពោះអ្នកវិនិយោគិន**

ការវិនិយោគសាធារណៈ ត្រូវទទួលបានការបន្ថយពន្ធ៥០(ហាសិប)ភាគរយទៅលើការប្រាក់ និងភាគលាភដែលបានកាន់កាប់ និងការទិញលក់មូលបត្ររដ្ឋ មូលបត្រកម្មសិទ្ធិ និងមូលបត្របំណុល សម្រាប់រយៈពេល៣(បី)ឆ្នាំ គិតចាប់ពីដំណើរការទីផ្សារមូលបត្រ។

**ក្រុមហ៊ុនដែលមិនត្រូវបានទទួលការលើទឹកចិត្តពន្ធលើប្រាក់ចំណូល**(Profit Tax)

ក្រុមហ៊ុនមិនត្រូវបានទទួលការលើទឹកចិត្តពន្ធលើប្រាក់ចំណូល(Profit Tax)ដូចដែលបានចែងក្នុងមាត្រ៤នៃអនុក្រឹត្យនេះឡើយ ក្នុងករណីក្រុមហ៊ុននោះជាសហគ្រាសវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលកំពុងស្ថិតនៅក្នុងរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល (Profit Tax)ដូចមានចែងក្នុងច្បាប់ និងបទបញ្ញាតិស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

**ការបញ្ឈប់ពីការលើទឹកចិត្តរបស់ពន្ធដារ**

អគ្គនាយកអាចស្នើសុំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមរយៈគ.ម.ក ដើម្បីបញ្ឈប់ការ លើកទឹកចិត្តពន្ធដារ ដូចមានចែងក្នុងមាត្រា៤នៃអនុក្រឹត្យនេះ ក្នុងករណីក្រុមហ៊ុនបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និងមូលបត្របំណុលជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពីគ.ម.ក និង ការចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត៖

-មិនបានដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែនិង បង់ប្រាក់ពន្ធតាមកាលកំណត់របស់រដ្ឋបាសារពើពន្ធ។

-មិនបានដាក់លិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំសម្រាប់ឆ្នាំសារពើពន្ធនិងបង់ប្រាក់ពន្ធតាមកាកំណត់របស់រដ្ឋបាលសារពើពន្ធ។ក្រុមហ៊ុនគណនេយ្យជំនាញផ្តល់សេវាក្នុងវិស័យមូលបត្ររួមមាន៖

របាយការណ៍តុល្យការ ,របាយការណ៍លទ្ធផល, របាយការណ៍លំហូរសាច់ប្រាក់ និងកំណត់សំគាល់ដោយមិនឱ្យហួសពីរយៈពេល៣(បី)ខែក្រោយពីដំណាច់ឆ្នាំសារពើពន្ធ។

-មិនអនុញ្ញាតឱ្យរដ្ឋបាលសារពើពន្ធធ្វើសវនកម្មលើបញ្ជីគណនេយ្យ ឬ ឯកសារផ្សេងៗ។

-មិនបានបង់ពន្ធអាករទាំងអស់ ពន្ធបន្ថែម និងការប្រាក់ដែលកំណត់រយៈពេលជាប់ពន្ធដែលបានធ្វើសវនកម្មរួចដោយរដ្ឋបាលសារពើពន្ធ។

## ៣.៣ ផលប្រយោជន៍នៃការជួញដូរមូលបត្រ ចំពោះសេដ្ឋកិច្ច និងសង្គម

### ៣.៣.១ ផលប្រយោជន៍របស់ទីផ្សារមូលបត្រ

**ទីផ្សារមូលបត្រ (Securities Market)** គឺជាកន្លែងសម្រាប់ធ្វើការជួញដូរមូលបត្រ និងឧបករណ៍ហិរញ្ញវត្ថុដទៃទៀត។ តាមនិយមន័យច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន "សំដៅដល់ទីផ្សារ ឬទីកន្លែងជួញដូរមូលបត្រ ឬ ប្រព័ន្ធដែលផ្តល់មធ្យោបាយនៃការធ្វើសំណើលក់ ផ្ទេរ ឬការទិញ-លក់មូលបត្រ" ឧបករណ៍ហិរញ្ញវត្ថុដែលតែងតែត្រូវបានជួញដូរលើទីផ្សារនេះ រួមមានមូលបត្រកម្មសិទ្ធិ មូលបត្របំណុល និងឧបករណ៍និស្សន្ទជាដើម។

**ទីផ្សារមូលបត្រ** គឺជាកត្តាមូលដ្ឋានមួយយ៉ាងសំខាន់សម្រាប់សេដ្ឋកិច្ចគេតែងតែនិយាយថា ទីផ្សារមូលបត្រគឺជានិមិត្តរូបនៃសេដ្ឋកិច្ចជាតិមួយទាំងមូល។ ជាការពិតណាស់រាល់បម្រែបម្រួលនៃបរិបទជាតិ និងអន្តរជាតិ (សេដ្ឋកិច្ច-សង្គម និងនយោបាយ) វានឹងធ្វើឱ្យមានផលប៉ះពាល់ទៅដល់ទីផ្សារមូលបត្រភ្លាមដោយគ្រាន់តែមើលទៅលើសន្ទស្សន៍ហ៊ុន គេនឹងឃើញពីឥទ្ធិពលរបស់ទីផ្សារមូលបត្រលើសេដ្ឋកិច្ចយ៉ាងណាពីព្រោះសន្ទស្សន៍ហ៊ុនរបស់ផ្សារមូលបត្រ វាបានឆ្លុះបញ្ចាំងពីស្ថានភាពសេដ្ឋកិច្ចជាតិ។ ហេតុនេះ ស្ទើរតែគ្រប់បណ្តាប្រទេសអភិវឌ្ឍទាំងអស់ មានទីផ្សារមូលបត្រនេះ ហើយវាបានដើរតួនាទីយ៉ាងសំខាន់ចំពោះសេដ្ឋកិច្ចជាតិ៖

-ទីផ្សារមូលបត្រជួយជំរុញឱ្យមហាជនបង្កើននូវការសន្សំ និងកៀរគរមូលធនដែលនៅសេសសល់ មិនមានតម្រូវការប្រើប្រាស់យកទៅវិនិយោគក្នុង សេដ្ឋកិច្ច។

-ទីផ្សារមូលបត្រ គឺជាមធ្យោបាយមួយប្រមែប្រមូលកៀរគនូវប្រភពមូលធនដែលនៅទំនេរតូចៗ មិនទាន់មានតម្រូវការប្រើប្រាស់ ពូនផ្តុំជាមូលធនធំមួយដើម្បីវិនិយោគក្នុងវិស័យសេដ្ឋកិច្ចរូបវន្ត។

-ទីផ្សារមូលបត្រ គឺជាឧបករណ៍មួយជួយសម្រួលដល់រដ្ឋាភិបាល ក្នុងការអនុវត្តន៍នូវកម្មវិធី អភិវឌ្ឍន៍សេដ្ឋកិច្ច និង សង្គម ដើម្បីទាក់ទាញ និងស្រូបយកនូវមូលធនពីបរទេស។

-ទីផ្សារមូលបត្រជួយជំរុញឱ្យ បណ្តាក្រុមហ៊ុននានាប្រកបអាជីវកម្មដោយប្រសិទ្ធភាពមានតម្លាភាព។

-ទីផ្សារមូលបត្រជួយជំរុញឱ្យប្រភពមូលធនក្នុងស្រុកមានចរាចរ ឬចលនារស់រវើក។

-ទីផ្សារមូលបត្រជួយបង្កើតនូវទម្លាក់នៃការវិនិយោគ។

### ៣.៣.២ ផលប្រយោជន៍ប្រព័ន្ធទីផ្សារមូលបត្រ

ប្រព័ន្ធទីផ្សារមូលបត្រមានផលប្រយោជន៍ ដូចជា៖

ក.ទីផ្សារមូលបត្រគឺជាទីកន្លែងលក់មូលបត្រភាគហ៊ុន និងមូលបត្របំណុល

ខ.ជួយធ្វើឱ្យក្រុមហ៊ុនគ្រួសារ ក្លាយទៅជា ក្រុមហ៊ុនសាធារណៈដែលអាចដកទុនបានយ៉ាងងាយស្រួលបំផុត

គ.ជួយទាក់ទាញទុនអ្នកវិនិយោពីក្នុងនិងក្រៅប្រទេសមកពង្រីកក្រុមហ៊ុន

ឃ.ជួយឲប្រាក់ចំណូលបុគ្គលិកសល់ទំនេក្លាយទៅជា ប្រាក់វិនិយោគដែលជួយបង្កើនប្រាក់ចំណូលថែមទៀតតាមរយៈចំណូលពីភាគលាភនិងចំណូលពីការប្រាក់

ង.ជួយកាត់បន្ថយអំពើពុករលួយនៅក្នុងក្រុមហ៊ុន និងសង្គម

ច.ជួយកាត់បន្ថយអត្រាអត់ការងារធ្វើ

ឆ.ជួយកាត់បន្ថយអត្រាភាពក្រីក្រ

ជ.ធ្វើជួយឱ្យចំណូលពន្ធកើនឡើង

ឈ.ធ្វើជួយឱ្យ GDP កើនឡើង។

### ៣.៣.៣អត្ថប្រយោជន៍ទីផ្សារភាគហ៊ុនចំពោះវិនិយោគគិន

#### ក. ចំពោះសេដ្ឋកិច្ចជាតិ

-ទីផ្សារភាគហ៊ុនធ្វើឱ្យមានលំហូរសាច់ប្រាក់ពីក្រុមហ៊ុនដែលត្រូវការដើមទុន ទទួលបានមូលធនដោយផ្ទាល់ពីវិនិយោគិន។

-ទីផ្សារភាគហ៊ុន ធ្វើឱ្យក្រុមហ៊ុនមានលទ្ធភាពពង្រីកអាជីកម្មរបស់ខ្លួន ដូចនេះផលិតកម្មក៏កើនឡើង ហើយប្រាក់ចំណូលក៏កាន់តែច្រើន មានន័យថាផលិតផលក្នុងស្រុកមានកំណើន ដែលចូលរួមចំណែកដល់កំណើនសេដ្ឋកិច្ចជាតិ។

-វិស័យនានាក៏មានការរីកចម្រើន ដោយភាគហ៊ុនិកដើម អាចលក់ភាគហ៊ុនរបស់ខ្លួនក្នុងថ្លៃខ្ពស់ នឹងយកទៅវិនិយោគក្នុងវិស័យថ្មី។

-ចំណូលជាតិមានការកើនឡើង ព្រោះអាជីវកម្មរបស់ក្រុមហ៊ុនរីកចម្រើន នោះក្រុមហ៊ុននឹងត្រូវបង់ពន្ធកាន់តែច្រើន។

-ទីផ្សារភាគហ៊ុន គឺជាសូចនាករមួយដែលអាចអោយយើងព្យាករណ៍ពីស្ថានភាពសេដ្ឋកិច្ចជាតិពេលអនាគត តាមរយៈ ការប្រែប្រួលសន្ទស្សន៍ផ្សារបច្ចុប្បន្ន។

-ជំរុញឱ្យមានការវិនិយោគបន្ថែមរបស់ក្រុមហ៊ុន និងបង្កើនការងារក្នុងស្រុក។

-និងទាក់ទាញអោយមានការវិនិយោគដោយផ្ទាល់ពីបរទេស (Foreign Direct Investment)

#### ខ.ចំពោះវិនិយោគិន

-ទទួលបាននូវប្រាក់ចំណេញ នៅពេលថ្លៃភាគហ៊ុនកើនឡើង

-ជាប្រភពចំនូលបន្ថែម បន្ទាប់ពីការងារប្រចាំថ្ងៃ ដោយវិនិយោគិននឹងអាចទទួលបានភាគលាភ ទៅតាមស្ថាន ក្លាយជាភាគហ៊ុននិករបស់ក្រុមហ៊ុន ដោយមិនចាំបាច់មានដើមទុនច្រើន។ ការជួញដូរភាគហ៊ុននៅកម្ពុជា អនុញ្ញាត្តិចាប់ពីមួយហ៊ុនឡើងទៅ។

-មានការលើកទឹកចិត្តពន្ធទៅលើភាគលាភ ដែលទទួលបាន និងពន្ធនានា ទទួលបាននូវការវិនិយោគថ្មីមួយទៀត បន្ថែមពីវិនិយោគផ្សេងៗ និងអាចជ្រើសរើសភាគហ៊ុនរបស់ក្រុមហ៊ុនក្នុងវិស័យខុសៗគ្នា ឬអាចនិយាយថាជាឱកាសវិនិយោគមួយបន្ថែមទៀតលើការបើកអាជីវកម្មរកស៊ីខ្លួនឯង ឬ ចូលហ៊ុនធ្វើអាជីវកម្មជាមួយបងប្អូន ឬ មិត្តភ័ក្រ្ត។

-បង្កើតទំលាប់សន្សំ និងវិនិយោគ និងភាពសារជីវកម្មរបស់ក្រុមហ៊ុន។

ហេតុផល៤យ៉ាងធំៗដែលអ្នកត្រូវវិនិយោគភាគហ៊ុន៖

**១ ឱកាសវិនិយោគ និងប្រាក់ចំណេញ**

ជំនួសឱ្យ ឬបន្ថែមលើការបើកអាជីវកម្មផ្ទាល់ខ្លួន ការកាន់កាប់ភាគហ៊ុនផ្តល់ឱ្យវិនិយោគិននូវឱកាសដើម្បីចូលរួមក្នុងអាជីវកម្មដែលមិនចាំបាច់មានជំនាញ និងបទពិសោធជាក់លាក់ ឬការគ្រប់គ្រងដោយផ្ទាល់នោះទេ។ ទន្ទឹមនឹងនេះ ប្រាក់ចំណេញពីការជួញដូរ និងការកាន់កាប់ភាគហ៊ុនអាចមានផលចំណេញខ្ពស់ដែលបានមកពីការចែកភាគលាភ និងការចំណេញពីការលក់ភាគហ៊ុន។

**២ .ផ្តល់លទ្ធភាពសម្រាប់ការវិនិយោគតូចៗ**

ទីផ្សារភាគហ៊ុនអនុញ្ញាតឱ្យវិនិយោគិនដែលមានប្រាក់សមល្មម អាចវិនិយោគលើក្រុមហ៊ុនធំ ហើយទទួលបានផលចំណេញមកវិញដូចទៅនឹងបុគ្គល ឬស្ថាប័នដែលវិនិយោគក្នុងទឹកប្រាក់ច្រើន ដោយផ្អែកលើសមាមាត្រកាន់កាប់របស់ពួកគេ។

**៣,ការធ្វើពិពិធកម្មវិនិយោគ**

ក្រៅពីប្រភពចំណូលសំខាន់ៗ របស់អ្នក ដូចជាប្រាក់ខែ ឬប្រាក់ចំណេញពីអាជីវកម្ម និងប្រាក់ចំណូលបន្ថែមផ្សេងទៀត ដូចជាការប្រាក់ពីប្រាក់បញ្ញើសន្សំនៅធនាគារ ការជួលផ្ទះ ឬការវិនិយោគលើអចលនទ្រព្យ អ្នកអាចវិនិយោគនៅក្នុងផ្សារហ៊ុន ដើម្បីធ្វើពិពិធកម្មវិនិយោគ។

**៤. មានទីផ្សារដែលអាចទិញលក់ប្រចាំថ្ងៃ**

ការវិនិយោគលើភាគហ៊ុនមានលក្ខណពិសេស ជាងការវិនិយោគលើទ្រព្យសកម្មដទៃ ដោយហេតុថាទីផ្សារភាគហ៊ុនមានរចនាសម្ព័ន្ធពេញលេញ ដែលអនុញ្ញាតឱ្យវិនិយោគិន ទិញ លក់ បានប្រចាំថ្ងៃនៅក្នុងផ្សារមូលបត្រ ។ ក្នុងន័យនេះ គឺវិនិយោគិនអាចបង្វែរភាគហ៊ុន ទៅជាសាច់ប្រាក់បានយ៉ាងងាយ ក្នុងផ្សារមូលបត្រតាមរយៈការជួញដូរ ដែលធ្វើឡើងជារៀងរាល់ថ្ងៃ។ ផ្ទុយទៅវិញ ការវិនិយោគដោយផ្ទាល់ទៅក្នុងអាជីវកម្ម ឬ អចលនទ្រព្យ មិនបានផ្តល់លក្ខណៈងាយស្រួល ក្នុងការបង្វែរជាសាច់ប្រាក់ ដូចការវិនិយោគលើភាគហ៊ុនឡើយ។

**៣.៣.៤ សុវត្ថិភាពនៃការជួញដូរមូលបត្រកម្ពុជា**

ផ្សារមូលបត្រកម្ពុជា គឺជាទីផ្សារមួយ និងដំបូងគេបង្អស់ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជាសម្រាប់ឱ្យវិនិយោគគិនដែលចង់វិនិយោគលើមូលបត្រ និងក្រុមហ៊ុនដែលមានបំណងចង់បោះផ្សាយភាគហ៊ុន ឫមូលបត្របំណុលរបស់ខ្លួនជាលើកដំបូងនៅទីនោះ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះវិស័យមូលបត្របានចូលរួមចំណែកយ៉ាងច្រើនក្នុងសហការពង្រីកនិងពង្រឹង វិស័យហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជាផងដែរ។ ប៉ុន្តែវិស័យមួយនេះនៅតែមានចំណោតបញ្ហាសម្រាប់បងប្អូនប្រជាជនខ្មែរដែលមិនសូវមានទំនុកចិត្តក្នុងការវិ

និយោគក្នុងទីផ្សាមួយនេះ។ កត្តាមួយចំនួន ដែលអាចធ្វើឱ្យយើងសន្និដ្ឋានបានជាការវិនិយោគ ក្នុងទីផ្សាមួយនេះពិតជាមានសុវត្ថិភាព។

១.ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ជាមួយក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានសហការជាមួយក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ នៅក្នុង ឆ្នាំ២០០៩ ក្រោមកិច្ចព្រមព្រៀងក្រុមហ៊ុនចំរុះមួយ។ នៅក្នុងនោះរាជរដ្ឋាភិបាលកម្ពុជាដែលមានតំណាងជាក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុបានកាន់កាប់ភាគហ៊ុនចំនួន៥៥%និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េកាន់កាប់៤៥%។

២.ទទួលបានអាជ្ញាបណ្ណពីគណៈកម្មការមូលបត្រកម្ពុជា(គ.ម.ក)។ (គ.ម.ក) គឺជាគឺជាអាជ្ញាធរគ្រប់គ្រងវិស័យមូលបត្រកម្ពជា និងមានមុខងារសម្រាប់កំណត់លក្ខខណ្ឌសម្រាប់ផ្តល់អាជ្ញាបណ្ណ័ជូនក្រុមហ៊ុនមូលបត្រនិង ភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ។ ក្នុងនោះប្រកាសលេខ០០៦ ឆ្នាំ២០១១ ស្តីពី«ការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្រ»របស់ក្រុមហ៊ុនទីផ្សារមូលបត្រកម្ពុជាពោលគឺមានន័យថាផ្សារមួយនេះមានការទទួលស្គាល់ត្រឹមត្រូវពីអាជ្ញាធរ។

៣.មានក្រុមហ៊ុនធំៗជាច្រើនបានមកចុះបញ្ជីពេលបច្ចុប្បន្ននេះ។ មានក្រុមហ៊ុនធំៗចំនួន១៣បានធ្វើការបោះផ្សាយលក់មូលបត្រ របស់ខ្លួនក្នុងទីផ្សារមូលបត្រនេះ។ ក្រុមហ៊ុនទាំងអស់នេះសុទ្ធ តែតម្រូវឱ្យឆ្លងកាត់ការចុះបញ្ជីជាមុនដែល នៅក្នុងនោះតម្រូវឱ្យមានក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមមេធាវី ឬ មេធាវី។

ក្រុមហ៊ុនគណនេយ្យជំនាញនិង ក្រុមហ៊ុនវាយតម្លៃជាដើមសម្រាប់ជួយកែតម្រូវនិងសម្រួលដល់និតិវិធីចូលទីផ្សារ។

៤.ប្រព័ន្ធជួញដូរចល័ត ឬ MTS ជាប្រព័ន្ធត្រូវបានបង្កើតឡើងដោយក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាក្នុងគោលបំណងជួយសម្រួលដល់ការជួញដូរឱ្យមានភាពរហ័សសុវត្ថិភាពនិង ងាយស្រួលសម្រាប់វិនិតោគគិន។ ម្យាងទៀតតាមរយៈ ទូរសព្ទ័ដៃរដែលភ្ជាប់ជាមួយអ៊ីនធឺណោតបងប្អូនអាចធ្វើការបញ្ជាទិញលក់ដោយខ្លួនឯងពិនិត្យតាមដានមើលទិន្នន័យទីផ្សាបានជាប្រចាំផងដែរ។

៥.ការចូលរួមពីរាជរដ្ឋាភិបាល រាជរដ្ឋាភិបាលកម្ពុជាក៏បានចូលរួមនិងមានការគាំទ្រយ៉ាងសកម្មដល់អ្នកវិនិយោគមូលបត្រខាងក្រោមរូបភាពផ្តល់ជាការលើកទឹកចិត្ត ពន្ធដារក្នុងវិស័យមូលបត្រ។ ក្នុងនោះការលើកលែងពន្ធកាត់ទុកដល់អ្នកវិនិយោគមូលបត្រគឺ ផ្តល់ឱ្យ អ្នកវិនិយោគសាធារណៈ និងទទួលបាន ការកាត់បន្ថពន្ធកាត់ទុក៥០%លើការប្រាក់និងភាគលាភដែលបានមកពីការជួញដូរ ឬ កាន់កាប់មូលបត្ររដ្ឋ មូលបត្រកម្មសិទ្ធិ និងមូលបត្របំណុលសម្រាប់រយៈពេល៣ឆ្នាំ គិតចាប់ពីថ្ងៃដែលអនុក្រឹត្យចូលជាធរមានក្នុងឆ្នាំ២០០៩។ ហេតុដូចនេះហើយទើបអាចសន្និដ្ឋានបានថា ក្រុមហ៊ុនផ្សាមូលបត្រកម្ពុជាជាកន្លែងមួយដែលអាចឱ្យយើងទុកចិត្តសម្រាប់ធ្វើការវិនិយោគមូលបត្រ។

តាមរយៈតួនាទីនេះ(គ.ម.ក)មានជំនឿយ៉ាងមុតមាំថាយើងអាចទាញយកផលប្រយោជន៍យ៉ាងច្រើនសម្រាប់ទីផ្សារមូលបត្រនៅកម្ពុជា និងសមាជិកផ្សេងៗទៀតជាពិសេសរសមាជិកទីផ្សារមូលបត្រនៅមានភាពក្មេងខ្ចីនៅឡើយដូចជាទីផ្សារមូលបត្រកម្ពុជាជាដើម។

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

ក្នុងនាមក្រុមយើងខ្ញុំជានិស្សិតសរសេរសារណាបញ្ចប់ការសិក្សា ដែលសរសេរស្តីពី "**ការជួញដូរមូលបត្រជាសាធារណៈនៅកម្ពុជា**" បានមើលឃើញថា ទីផ្សារមូលបត្រ គឺជាមូលដ្ឋានមួយយ៉ាងសំខាន់សម្រាប់សេដ្ឋកិច្ចជាតិ គេតែងនិយាយថា ទីផ្សារមូលបត្រ គឺជានិមិត្តរូបនៃសេដ្ឋកិច្ចជាតិមួយទាំង មូល។ ហេតុដូចនេះទើបមានចំណុចខ្លាំង និងចំណុចខ្សោយដូចខាងក្រោម៖

## ៤.១ ការវិភាគលើចំណុចខ្លាំង

ចំណុចខ្លាំងនៃដំណើរការជួញដូរមូលបត្រជាសាធារណៈ (Public Securities Trading) នៅកម្ពុជាអាចរៀបរាប់បានដូចខាងក្រោម៖

**. ការគ្រប់គ្រងតាមរយៈគ្រឹះស្ថានច្បាស់លាស់ និងមានសុវត្ថិភាពខ្ពស់**

ដំណើរការជួញដូរមូលបត្រជាសាធារណៈត្រូវបានគ្រប់គ្រងដោយ អាជ្ញាធរទទួលបន្ទុកផ្សារមូលបត្រកម្ពុជា (SECC) ដែលមានបេសកកម្មចម្បងក្នុងការដោះស្រាយ ប្រតិបត្តិ និងត្រួតពិនិត្យប្រតិបត្តិការមូលបត្រប្រកបដោយសុវត្ថិភាព ត្រឹមត្រូវ និងស្មើភាព។ ការដាក់ច្បាប់ និងបទប្បញ្ញត្តិជាច្រើនពី SECC ជួយធានាថាក្រុមហ៊ុន និងវិនិយោគិនទាំងឡាយអាចស្របច្បាប់ និងទទួលបានការការពារសិទ្ធិ។

**. ប្រព័ន្ធបច្ចេកវិទ្យា និងបច្ចេកទេសទំនើប**

ផ្សារមូលបត្រកម្ពុជាបានប្រើប្រាស់ ប្រព័ន្ធជួញដូរដោយស្វ័យប្រវត្តិ (Automated Trading System - ATS) ដែលផ្តល់នូវភាពរហ័ស និងត្រឹមត្រូវក្នុងការជួញដូរ។ ប្រព័ន្ធនេះអាចធានាបាននូវភាពថ្លៃថ្នូរ សុវត្ថិភាពនៃទិន្នន័យ និងការធ្វើប្រតិបត្តិការជួញដូរ ដោយគ្មានការប៉ះពាល់ពីបុគ្គលជាក់លាក់ ឬអារម្មណ៍ផ្សេងៗ។

**. ការចូលរួមរបស់រដ្ឋាភិបាលក្នុងការជំរុញសេដ្ឋកិច្ចតាមរយៈផ្សារ**

រដ្ឋាភិបាលកម្ពុជាបានដាក់ចិត្តច្រើនលើការអភិវឌ្ឍផ្សារមូលបត្រដោយផ្តល់ការឧបត្ថម្ភតម្លៃពន្ធពិសេស ការអប់រំសាធារណជន និងការចាត់ទុកឱ្យវិស័យនេះជាគន្លងសំខាន់សម្រាប់ប្រមូលមូលនិធិវិនិយោគក្នុងវិស័យសង្គម និងសេដ្ឋកិច្ច។

**. កែលម្អភាពថ្លៃថ្នូរនៃការផ្តល់ព័ត៌មានហិរញ្ញវត្ថុ**

ក្រុមហ៊ុនដែលចូលបញ្ជីក្នុងផ្សារ ត្រូវបង្ហាញរបាយការណ៍ហិរញ្ញវត្ថុយ៉ាងច្បាស់លាស់ ប្រចាំត្រីមាស និងប្រចាំឆ្នាំ ជាមួយនឹងការត្រួតពិនិត្យពីស្ថាប័នឯករាជ្យ។ នេះជួយបង្កើនទំនុកចិត្តពីវិនិយោគិន និងបញ្ចប់ការប្រព្រឹត្តខុសច្បាប់។

**. ការចូលរួមជាថ្មីរបស់វិស័យឯកជន និងវិនិយោគិនអន្តរជាតិ**

កម្ពុជាកំពុងទាក់ទាញវិនិយោគិនអន្តរជាតិ ដោយសារតែភាពស្ងប់ស្ងាត់នៃទីផ្សារ ស្ថិរភាពនយោបាយ និងសេដ្ឋកិច្ចកំពុងរីកចម្រើន។ ការចូលរួមពីក្រុមហ៊ុនឯកជន ក្នុងទីផ្សារមូលបត្រច្រើនកាន់តែជំរុញឱ្យមានកំណើននៃដំណើរការជួញដូរ។

**. ការអប់រំហិរញ្ញវត្ថុ និងការផ្សព្វផ្សាយសាធារណៈ**

អាជ្ញាធរទទួលបន្ទុកផ្សារមូលបត្រកម្ពុជា និងស្ថាប័នពាក់ព័ន្ធបានប្រារព្ធកម្មវិធីសិក្សាសាធារណៈ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់នៃវិនិយោគ។

**. វិស័យហិរញ្ញវត្ថុសរុបកំពុងរីកចម្រើន**

ជាមួយនឹងការវិវឌ្ឍន៍លឿននៃវិស័យធនាគារ សារពើពន្ធ និងបន្តការចូលរួមរបស់ FinTech និង Mobile Banking ផ្សេងៗ នេះជួយជំរុញដល់ការចូលរួមវិនិយោគក្នុងផ្សារមូលបត្រជាសាធារណៈ។

## ៤.២ វិភាគលើចំណុចខ្សោយ

ទន្ទឹមនឹងភាពវិជ្ជមានដែលលើកឡើងខាងលើ តាមរយៈការស្រាវជ្រាវរបស់ ក្រុមនាងខ្ញុំក៏មើលឃើញពីកង្វះខាតមួយចំនួន ដែលតម្រូវឱ្យមានការយកចិត្តទុកដាក់បន្ថែមដើម្បីឱ្យ "ការជួញដូរមូលបត្រនៅកម្ពុជា" កាន់តែប្រសើរឡើងដូចជា៖

**. ការណែនាំ**

ទីផ្សារមូលបត្រជាសាធារណៈ (Capital Market) ជាឧបករណ៍សំខាន់សម្រាប់ការរីកចម្រើនសេដ្ឋកិច្ចជាតិ។ ទោះបីបានចាប់ផ្តើមអភិវឌ្ឍន៍តាំងពីដើមទសវត្សរ៍ ២០១០ តទៅ ក៏ដោយ ទាំងនៅក្នុងផ្នែកសារពើភណ្ឌ (Cambodia Securities Exchange - CSX) និងសេវាហិរញ្ញវត្ថុពាក់ព័ន្ធផ្សេងៗ ក៏ទីផ្សារនេះនៅតែប្រឈមមុខនឹងបញ្ហាច្រើន។

**. ការយល់ដឹងនិងការចូលរួមតិចតួចពីសាធារណៈ**

មូលបត្រជាសាធារណៈនៅកម្ពុជានៅតែជារឿងថ្មីសម្រាប់ប្រជាពលរដ្ឋភាគច្រើន។

**. សកម្មភាពជួញដូរនៅកម្រិតទាប និងភាពងាយរងគ្រោះ**

ទោះបីមានការដាក់ឱ្យដំណើរការមូលបត្រជាសាធារណៈដោយក្រុមហ៊ុនជាតិមួយចំនួន។

**. កង្វះការបង្ហាញព័ត៌មានដោយសេរីនិងស្មោះត្រង់**

ការបង្ហាញព័ត៌មានពាក់ព័ន្ធនឹងលទ្ធផលហិរញ្ញវត្ថុ និងសកម្មភាពប្រតិបត្តិការរបស់ក្រុមហ៊ុនសាជាណៈមួយចំនួននៅតែខ្វះភាពច្បាស់លាស់។

**. ច្បាប់ និងការត្រួតពិនិត្យមិនទាន់រឹងមាំ**

បន្ទាប់ពីការបង្កើតសារពើភណ្ឌនិងស្ថាប័នគ្រប់គ្រងដូចជាស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុកម្ពុជា។

**. បរិស្ថានសេដ្ឋកិច្ចនិងការស្ថិរភាព**

បរិស្ថានសេដ្ឋកិច្ចក្នុងប្រទេសអាចប៉ះពាល់យ៉ាងខ្លាំងដល់ការជឿជាក់របស់អ្នកវិនិយោគ។

**. ការកែប្រែបច្ចេកវិទ្យានិងសេវាកម្មជំនួយមិនទាន់ទូលំទូលាយ**

ប្រព័ន្ធតេស្តសម្រាប់ការជួញដូរមូលបត្រនៅតែមានការកំណត់។

**. ភាពខ្វះជំនាញបុគ្គលិកផ្នែកវិនិយោគ**

សកម្មភាពជួញដូរមូលបត្រត្រូវការជំនាញខ្ពស់ក្នុងការវិភាគព័ត៌មានហិរញ្ញវត្ថុ។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និង អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

ក្នុងនាមក្រុមយើងខ្ញុំជានិស្សិតសរសេរសារណាបញ្ចប់ការសិក្សាដែលសរសេរស្តីពី "**ការជួញដូរមូលបត្រជាសាធារណៈនៅកម្ពុជា**" បានមើលឃើញថាការជួញដូរមូលបត្រ និងទីផ្សារមូលបត្រពិតជាមានសារៈសំខាន់ណាស់ក្នុងការជួយពង្រឹងដល់សេដ្ឋកិច្ចជាតិ។ ការសម្រេចបាននូវកំណើន សេដ្ឋកិច្ច គឺជាគោលដៅ ដ៏ចម្បងរបស់ប្រទេសនានាក្នុងសកលលោក។កំណើនសេដ្ឋកិច្ចបង្កើតការងារកាន់តែច្រើនបង្កើនប្រាក់ចំណូល កាត់បន្ថយភាពក្រីក្រ និងលើកស្ទួយជីវភាពរបស់ប្រជាពលរដ្ឋ។ ទោះយ៉ាងណាក្តីដើម្បីសម្រេចបានកំណើននេះប្រទេ នីមួយត្រូវប្រើប្រាស់ធនធានឱ្យមានប្រសិទ្ធិភាពដើម្បីបង្កើនផលិតផល និងសេវាកម្មកាន់តែ ច្រើនទៅកាន់ទីផ្សារ។ទីផ្សារមូលបត្រដើរតួនាទីយ៉ាងសំខាន់ក្នុងការឆ្លើយតបទៅ នឹងតម្រូវការនេះតាមរយៈការកៀរគរមូលធនដែលចាំបាច់សម្រាប់នវានុវត្តន៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសហគ្រាសធំៗ និងសហគ្រាស ធុន តូច និងមធ្យមប្រកបដោយប្រសិទ្ធភាព និងតម្លាភាព។

បន្ថែមពីនេះ ផ្សារមូលបត្រដើរតួនាទីយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ចរបស់ប្រទេសមួយ ដោយវាអនុញ្ញាតឱ្យក្រុមហ៊ុនសាជីវកម្ម សហគ្រាសសាធារណៈ និងរដ្ឋាភិបាលអាចប្រមូលទុនដោយផ្ទាល់ពីសាធារណជន មកប្រើប្រាស់ដើម្បីពង្រីកអាជីវកម្ម ឬអភិវឌ្ឍន៏ហេដ្ឋារចនាសម្ព័ន្ធជាដើម។ ម៉្យាងវិញទៀត អ្នកដែលមានប្រាក់សល់ពីការចំណាយ មានជម្រើសក្នុងការធ្វើពិពិធកម្មសំណុំវិនិយោគរបស់ខ្លួន ឬធ្វើការសន្សំ(ជាមួយមូលបត្រដែលមានហានិភ័យទាប) នៅក្នុងទីផ្សារមូលបត្រ។ នៅពេលដែលសាច់ប្រាក់ហូរពីអ្នកមាន ឬអ្នកដែលមានសាច់ប្រាក់លើសតម្រូវការ ទៅអ្នកដែលត្រូវការប្រកបដោយប្រសិទ្ធភាព ពេលនោះសកម្មភាពសេដ្ឋកិច្ចដូចជាផលិតកម្ម និងពាណិជ្ជកម្មនឹងរីកលូតលាស់ទៅតាមនោះដែរ ព្រមទាំងបង្កើតឱ្យមានការងារតាមរយៈការវិនិយោគបន្ថែម និងបង្កើនទ្រព្យសម្បត្តិសម្រាប់ប្រជាជនទូទៅ។

## ៥.២ ការផ្តល់អនុសាសន៍

បន្ទាប់ពីធ្វើការស្រាវជ្រាវយ៉ាងម៉ត់ចត់ "**ការជួញដូរមូលបត្រនៅជាសាធារណៈនៅកម្ពុជា**" មានការវិវឌ្ឍបានយ៉ាងច្រើន តាំងពីចាប់ផ្តើមរហូតមកដល់បច្ចុប្បន្នភាព។ ចំណុចខ្សោយរបស់ផ្សារមូលបត្រកម្ពុជាយើងដឹងហើយថាការជួញដូរមូលបត្រនៅមានកម្រិតនៅឡើយនៅក្នុងទីផ្សារ។ ភាពខ្សោយនៃតម្លៃហ៊ុនគឺដោយសារតែទីផ្សារមូលបត្រជាទីផ្សារថ្មីមួយដែលធ្វើអោយអ្នកជួញដូរមិនមានច្រើននៅក្នុងទីផ្សារ។ ហើយម្យ៉ាងទៀតផលិតផលនៅក្នុងទីផ្សារមូលបត្រមិនសូវសម្បូរបែបដែលជាហេតុនាំអោយទីផ្សារមូលបត្រនៅកម្ពុជាមានការចុះខ្សោយ។ រាល់ប្រតិបត្តិការទាំងអស់ដែលពាក់ព័ន្ធនៅក្នុងវិស័យមូលបត្រទាំងមូល គឺស្ថិតនៅក្រោមបទបញ្ញត្តិរបស់ច្បាប់ដែលមានការដាក់បង្ហាញនូវ ព័ត៌មាននានាជាសាធារណះដែលកាត់បន្ថយការក្លែងបន្លំព័ត៌ មានដែលផ្ទុយពីច្បាប់។ សេចក្តីថ្លែង ឬការផ្សព្វផ្សាយព័ត៌មានក្លែងបន្លំ ដែលនាំឱ្យមានការយល់ខុសធ្ងន់ធ្ងរ ដែលបណ្តាលឱ្យសាធារណជនទិញលក់មូលបត្រ ឬបណ្តាលឱ្យមានការកើនឡើង ឬថយចុះការ ឬនៅថេរចំពោះតម្លៃនៃការជួញដូរនៅក្នុងទីផ្សារមូលបត្រ។

# ឯកសារយោង


- វិទ្យាស្ថាន វ៉ាន់ដា. *ការគ្រប់គ្រងហិរញ្ញវត្ថុ*. បោះពុម្ពលើកទី៥(២០២៣) ទំព័រទី៩៦
- *ស្រង់ចេញពីហ្វេសប៊ុកឈ្មោះកាក់ សេន ផុសថ្ងៃ៣ ខែ១២ ឆ្នាំ២០២០*
- *ស្រង់ចេញពីសេចក្ដីកំណត់ចំពោះមាត្រានីមួយៗរបស់រដ្ឋប្បវេណី* ផ្នែកទី២ ទំព័រទី១
- វិទ្យាស្ថាន វ៉ាន់ដា. *មីក្រូសេដ្ឋកិច្ច*. បោះពុម្ពលើកទី៣(២០១២). ៧៥ទំព័រ
- LinkedIn. Sok Sotheara. (August, 14 2017). *មូលបត្រ(Securities)*. Retrieved June, 12 2025 from https://www.linkedin.com/pulse/មលបតរAsecurities-sok-sotheara
- E-Library INABA. Paul R. Krugman, Maurice Obstfeld, Marc J. Melitz. (2018). *International Economics Theory and Policy*. (11th edition). Retrieved 2025, June 12 from, *https://opaclib.inaba.ac.id/index.php?p=show_detail&id=1374&keywords=*
- Britannica Money, **Written by** Richard T. Vann. ***economic history.*** Retrieved July, 20 2025 from https://www.britannica.com/money/economic-history
- *Dokuman PUB ,English Pages [803] Year* 2017, *International Economics.* Retrieved July, 20 2025 from https://dokumen.pub/international-economics-theory-amp-policy-9780134519579-1292214872-9781292214870-2432743113-0134519574.html

# ឧបសម្ព័ន្ធ






